បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 6 ខែ 06 ឆ្នាំ 2003

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

០១-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៩៣ ស្តីពីការតែងតាំងឯកឧត្តម **គៀត សុគន្ធ** ជាទីប្រឹក្សាសម្តេចក្រុមព្រះ ប្រធានរដ្ឋសភា ២០៣០

០១-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៩៤ ស្តីពីការតែងតាំងឯកឧត្តម **កៅ គីមហួន** ជាទីប្រឹក្សាអមក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិទទួលបន្ទុកកិច្ចការអាស៊ាន ២០៣១

០៣-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៩៥ ស្តីពីការតែងតាំងឯកឧត្តម **ឡេង ណារ៉ុល** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋានក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ២០៣២

០៣-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៩៦ ស្តីពីការតែងតាំងឯកឧត្តម **គោស៊ី សារឿត** ជាអគ្គនាយកនៃក្រសួងទេសចរណ៍ ២០៣៣

០៥-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៩៧ ស្តីពីការតែងតាំងឯកឧត្តម **សូ ជុងហួរ** ជាឧកញ៉ា ២០៣៤

០៣-៨-២០០១ -ព្រះរាជក្រឹត្យនស/រកត/០៨០១/២៩៨ស្តីពីការតែងតាំងអគ្គសវនាករនិងអគ្គសវនាកររង នៃអាជ្ញាធរសវនកម្មជាតិ ២០៣៥

០៥-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៩៩ ស្តីពីការតែងតាំងឯកឧត្តម **គួយ ប៊ុនរឿន** ជាសមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រ ២០៣៦

០៧-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៦២ ស្តីពីការតែងតាំងឯកឧត្តម **ឡូនផន ស៊ីផុន** ជាឧកញ៉ា ២០៣៧

០៧-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៦៣ ស្តីពីការតែងតាំងៈ
១- ឯកឧត្តម **សំ សុផល** ជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់
២- ឯកឧត្តម **ស៊ុយ ម៉ុងលាង** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ២០៣៨

០៧-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៦៤ ស្តីពីការបង្កើតមជ្ឈមណ្ឌល សកម្មភាពកំចាត់មីនកម្ពុជា ហៅកាត់ថា មស.មក ២០៣៩

០៧-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៦៥ ស្តីពីការ តម្លើងឋានន្តរសក្តិថ្នាក់ឧត្តមសេនីយ៍ ទោជាកិច្ច បច្ឆាមរណៈចំពោះសពលោកឧត្តមសេនីយ៍ត្រី **ឡុង ថែម**
ថ្នាក់ឧត្តមសេនីយ៍ត្រីចំពោះសព
១-វរសេនីយ៍ឯក **ម៉ាញ យ៉ារិន**
២-វរសេនីយ៍ឯក **យ៉ាត ម្លេង** ២០៤៩

០៨-៨-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៨០១/២៦៦ ស្តីពីការតែងតាំងឯកឧត្តម **តូច សារ៉ា** ជាសមាជិកព្រឹទ្ធសភា ២០៥០

## II- ក្រុមប្រឹក្សាធម្មនុញ្ញ

### សេចក្តីសំរេច

០៧-៨-២០០១ -សេចក្តីសំរេចលេខ ០៤៣/០០៥/២០០១ កបធ.ច ២០៥១

## III-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

០១-៨-២០០១ -អនុក្រឹត្យលេខ ៧៣ អនក្រ បក ស្តីពីការចេញផ្សាយក្រដាសប្រាក់ប្រភេទ ១០០ រៀល គំរូថ្មី ២០៥៣
០៣-៨-២០០១ -អនុក្រឹត្យលេខ ៧៤ អនក្រ.បកស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្ម សហគ្រាសសាធារណៈ ២០៥៤
០៧-៨-២០០១ -អនុក្រឹត្យលេខ ៧៥ អនក្រ.បកស្តីពីការផ្ទេរឥណទានថវិកា ២០៥៦
០៨-៨-២០០១ -អនុក្រឹត្យលេខ ៧៦ អនក្រ.បកស្តីពីការរៀបចំ និងការប្រព្រឹត្តិរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ២០៥៨
០១-៨-២០០១ -អនុក្រឹត្យលេខ ៣២៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២០៧៧
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៧៩
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៨១
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៨៣
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៨៥
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៨៧
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៨៨
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៨៩
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៩០
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៩១
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៣៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៩២
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៤០ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ២០៩៣
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៤១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៩៤
០១-៨-២០០១ -អនុក្រឹត្យលេខ ៣៤២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៩៥

## គ


០១-៨-២០០១ -អនុក្រឹត្យលេខ ៣៤៣ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២០៩៦

០១-៨-២០០១ -អនុក្រឹត្យលេខ ៣៤៤ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ២០៩៧

០១-៨-២០០១ -អនុក្រឹត្យលេខ ៣៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២០៩៨

០១-៨-២០០១ -អនុក្រឹត្យលេខ ៣៤៦ អនក្រ.តត ស្តីពីការតែងតាំងលោក **គីម ហុង** ជាប្រធាននាយកដ្ឋាន សោធនអតីតយុទ្ធជននៃក្រសួងកិច្ចការនារីនិងអតីតយុទ្ធជន ២១០០

០១-៨-២០០១ -អនុក្រឹត្យលេខ ៣៤៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២១០១

០៣-៨-២០០១ -អនុក្រឹត្យលេខ ៣៤៨ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយទាហាន ២១០២

០៣-៨-២០០១ -អនុក្រឹត្យលេខ ៣៤៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១០៥

០៣-៨-២០០១ -អនុក្រឹត្យលេខ ៣៥០អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១០៦

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៥១អនក្រ.តត ស្តីពីការបំពាក់មេដាយសហមេត្រីថ្នាក់សេនា ជាកិច្ចបច្ឆាមរណៈ ជូនសពលោក អាត់ស៊ូអ៊ីតូ ណាតាកា (ATSUHITO NATAKA) អតីតយុវជនស្ម័គ្រចិត្តអង្គការសហប្រជាជាតិ ២១០៧

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៥២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ចំពោះលោកស្រី **ចំរើន មុនីតា** ប្រធានអង្គការស៊ីដសេ និងលោក **នួន វិចិត្រ** អនុប្រធាន ២១០៨

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិដល់ សប្បុរសជនខ្មែរចំនួន ០៦ រូប ២១០៩

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៥៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១១០

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៥៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១១២

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៥៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១១៣

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៥៧ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១១៤ស្ទួន

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៥៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិចំពោះ លោកយាយ **យ៉ាន ស** រស់នៅសហរដ្ឋអាមេរិក ២១១៥

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៥៩អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១១៦

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៦០ អនក្រ.តត ស្តីពីការបំពាក់មេដាយសហមេត្រី ថ្នាក់អស្សឫទ្ធិជូនលោក Hizoshi NISHIMIYA មន្ត្រីជំនាញការ ជប៉ុន ២១១៧

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៦១ អនក្រ.តត ស្តីពីការបំពាក់មេដាយស្ថាបនាជាតិ ជូនលោក **ភាគូ សារការអេ** ប្រធានអង្គការបំរើកុមារកម្ពុជា ២១១៨

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៦២ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១១៩

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៦៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១២០

# ឃ

០៧-៨-២០០១ -អនុក្រឹត្យលេខ ៣៦៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ២១២១

០៨-៨-២០០១ -អនុក្រឹត្យលេខ ៣៦៥ អនក្រ.តត ស្តីពីការតែងតាំងលោក **សាន វណ្ណឌី** ជាអគ្គនាយករង នៃក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ ២១២៣

## ២.សេចក្តីសម្រេច

០៣-៨-២០០១ -សេចក្តីសំរេចលេខ ៤៤ សសរ ស្តីពីការបង្កើតក្រុមការងារតាមវិស័យ សំរាប់ធ្វើជាគូពិភាក្សាការងារជាមួយវិស័យឯកជន ២១២៤

០៣-៨-២០០១ -សេចក្តីសំរេចលេខ ៤៥ សសរ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំថ្នាក់ជាតិ ចូលរួមក្នុងសន្និសិទកំពូលស្តីពីការអភិវឌ្ឍន៍ដោយចិរភាពឆ្នាំ ២០០២ ២១២៥

០៣-៨-២០០១ -សេចក្តីសំរេចលេខ ៤៦ សសរ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះ ឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ហៅកាត់ " ការិយាល័យសន្តិសុខថ្នាក់កណ្តាល" ២១៣២

០៧-៨-២០០១ -សេចក្តីសំរេចលេខ ៤៧ សសរ ស្តីពីការបន្ថែមសមាសភាពគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ហៅកាត់ " ការិយាល័យសន្តិសុខថ្នាក់កណ្តាល" ២១៣៤

០៨-៨-២០០១ -សេចក្តីសំរេចលេខ ៤៨ សសរ ស្តីពីការបង្កើតក្រុម ការងារសំរាប់រៀបចំគោល នយោបាយអភិវឌ្ឍន៍ថាមពលនិងឧស្ម័នជាតិ ២១៣៥

## ៣.សារាចរ

០៧-៨-២០០១ -សារាចរលេខ ០៤ សរ ស្តីពីការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីបសំពះព្រះខែ អកអំបុក និងពិធីខួបអនុស្សាវរីយ៍លើកទី៤៨ នៃបុណ្យឯករាជជាតិ ២១៣៨

## ៤.សេចក្តីអំពាវនាវ

០៧-៨-២០០១ - សេចក្តីអំពាវនាវលេខ ០១ សអ ២១៤១

# IV-ការងារបណ្តាក្រសួង

## ១.ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

### ប្រកាស

០៣-៨-២០០១ - ប្រកាសលេខ ៥១២ ឧរថ ឧតស.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូភើហ្គាស SUPER GAS Co Ltd ដែលមានលោក MAITREE YIM ជន ជាតិថៃជាប្រធាន បន្តដំណើរការឧស្សាហកម្មតូចបញ្ចូលឧស្ម័នសំរាប់ចង្ក្រានហ្គាស "អណ្តាតភ្លើង" នៅស្នាក់ការក្រុមហ៊ុនផ្លូវ ជាតិ លេខ៥ ភូមិដូង ឃុំព្រែក ព្នៅ ស្រុកពញាឮ ខេត្តកណ្តាល ២១៤២

០៨-៨-២០០១ -ប្រកាសលេខ ៥២១ ឧរថ ឧតស.ប្រក អនុញ្ញាតឱ្យក្រុមហ៊ុន ខេ & អេហ្គាមេនហ្វេក

ធើរីខូអិលធីឌី (K&A GARMENT Co .LTD) តំណាងដោយលោក KONG TSZ KA អាយុ ៤៩ឆ្នាំ ភេទប្រុសសញ្ជាតិអង់គ្លេស បង្កើតរោងចក្រកាត់ដេរ សំលៀកបំពាក់ ដែលមានឈ្មោះថា ខេ.អេហ្គាមេនមានទីតាំងស្ថិតនៅអតីតរោងចក្រ តម្បាញទី២ ផ្លូវជាតិលេខ៥ គីឡូម៉ែត្រលេខ៦ សង្កាត់ឫស្សីកែវ ខ័ណ្ឌឫស្សីកែវ រាជធានី ភ្នំពេញ ២១៤៣

**២.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

០៣-៨-២០០១ -ប្រកាសលេខ ២១៣ Moc/M2001 ស្តីពីលទ្ធផលនៃការដេញថ្លៃកូតា សំរាប់នាំ ចេញ សំលៀក បំពាក់ទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០១ ២១៤៥

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៤៣

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ពេទពញ្ញាផ្ដែក្នុងនៃរដ្ឋសភា ព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្ដីក្រាបបង្គំទូលរម្លឹកសុំរបស់សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា លេខ ៤៩២ រស ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០១

## ត្រាស់បង្គាប់

**មាត្រា១ ..** តែងតាំងឯកឧត្ដម គៀត សុគន្ធ ជាទីប្រឹក្សាសម្ដេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ទទួលបន្ទុកកិច្ចការហិរញ្ញវត្ថុ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

**មាត្រា២ ..** ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចតាម ព្រះរាជក្រឹត្យនេះ ។

**មាត្រា៣ ..** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ដលេខានេះតទៅ ។

ព្រះហស្ដលេខា

**នរោត្តម សីហនុ**

ភ្នំពេញ ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០០១

លេខ: ១៧៦ ធ.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែសីហា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សាខឹ តាន់**

# ព្រះរាជក្រឹត្យ

នស / រកត / ០៨០១ / ២៥៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ២០០១

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម គោរ គីមអ៊ិន ជាទីប្រឹក្សាអមក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទទួលបន្ទុកកិច្ចការអាស៊ាន មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០១

លេខៈ ១៧៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ៨/៧ ឆ្នាំ ២០០១

អគ្គលេខាធិការរង...

# ព្រះរាជក្រឹត្យ

នស / រកត /០៨០១/២៥៥

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០៩៩៩ / ១០ ចុះថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យច្បាប់ស្តីពីការបង្កើត ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០១

**ត្រាស់បង្គាប់**

**មាត្រា ១** : តែងតាំងឯកឧត្តម **ឡោច ណាល់** ជាអគ្គាធិការ នៃអគ្គាធិការដ្ឋាន ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន ។

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤** : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ១៧៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

តាន់

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១*

# ព្រះរាជក្រឹត្យ

នស / រកត /០៨០១/២៥៦

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងទេសចរណ៍
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០២ ខែ សីហា ឆ្នាំ ២០០១

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងឯកឧត្តម គោស៊ុំ សារឿត ជាអគ្គនាយក នៃក្រសួងទេសចរណ៍ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ១៧៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៥៧

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ឯកឧត្តម សួ ជុំខហួន

ជា

ឧកញ៉ា

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ១៦៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៥៨

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជបរិវង្ស ឧត្តមសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតសម្តែងការទុកចិត្តរបស់រដ្ឋសភា សម័យប្រជុំលើកទី ៦ នីតិកាលទី ២ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំង អគ្គសវនករ និងអគ្គសវនកររង នៃអាជ្ញាធរសវនកម្មជាតិ ដែលមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម អ៊ុត ឈន ជាអគ្គសវនករ

២- ឯកឧត្តម សេង រ៉ុន ជាអគ្គសវនកររង

៣- ឯកឧត្តម ស៊ិន ប៉ូ ជាអគ្គសវនកររង

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៤ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ ១៦៦ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ០៨ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ អាន

***រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០១***

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៥៩

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៨/០៤២ ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី ២
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតសម្តែងការទុកចិត្តរបស់រដ្ឋសភា សម័យប្រជុំលើកទី ៦ នីតិកាលទី ២ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១ :** តែងតាំងឯកឧត្តម **គួយ ប៊ុនរឿន** ជាសមាជិកនៃគណៈកម្មាធិការជាតិ រៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និង ឯកឧត្តម **គួយ ប៊ុនរឿន** ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

*រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០១*

លេខ ៦៧ ច.ល

ដើម្បីថតចម្លងជូន

រាជធានីភ្នំពេញ ០៨ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

ឯកឧត្តម ខួន ផុនស៊ីផុន

ជា

ឧកញ៉ា

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ ១៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវ តាន់

ភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦៣

**យើង**

**ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់អនុក្រឹត្យលេខ ១៣ អនក្រ ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតក្រុមប្រឹក្សាអ្នកច្បាប់
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

មាត្រា ១ : តែងតាំង :

១- ឯកឧត្តម **សំ សុខផល** ជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ រដ្ឋលេខាធិការ

២- ឯកឧត្តម **ស៊ុយ ម៉ុងលាង** ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ មានឋានៈស្មើ អនុរដ្ឋលេខាធិការ

មាត្រា ២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ១៧១ ច.ល

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

**រដ្ឋលេខាធិការរាជរដ្ឋាភិបាល**

**សុខ អាន**

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦៤

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍
## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការហាមប្រាម ការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីវិសោធនកម្មលើព្រះរាជក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់កម្ពុជា
- បានទ្រង់យល់ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៧ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពី ការតែងតាំងក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

# ត្រាស់បង្គាប់

## ជំពូកទី ១
## និតិសារជាតិនៃមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា

**មាត្រា ១ :**

ត្រូវបានបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ហៅកាត់ថា ម.ស.ម.ក. ។ ម.ស.ម.ក. ជាគ្រឹះស្ថានសាធារណៈរដ្ឋបាលមានលក្ខណៈជានីតិបុគ្គល ដែលស្ថិតនៅក្រោមអាណាព្យាបាលរបស់នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ។

ម.ស.ម.ក មានសិទ្ធិដើម្បី :

ក. ចុះកិច្ចសន្យា ឬបំពេញកាតព្វកិច្ចផ្សេងទៀត ដើម្បីអោយសំរេចបេសកកម្មរបស់ខ្លួន ។

ខ. ជ្រើសរើស និងប្រើប្រាស់បុគ្គលិកទាំងឡាយ ដែលចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

**មាត្រា ២ :**

ម.ស.ម.ក. ជាស្ថាប័នជាតិដែលផ្តល់សេវាកម្មផ្នែកបោសសំអាតមីនដើម្បីមូលហេតុមនុស្សធម៌ និង បោសសំអាតមីនតាមកម្មវិធីអភិវឌ្ឍន៍ ។ ម.ស.ម.ក. មានសិទ្ធិផ្តល់សេវាកម្មដូចខាងលើតាមកិច្ចសន្យានៃកម្មវិធីអភិវឌ្ឍន៍ទាំងនោះ ។

## ជំពូកទី ២
## គោលដៅ និង សកម្មភាព

**មាត្រា ៣ :**

ម.ស.ម.ក. ត្រូវបំពេញភារកិច្ចដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ។ ភារកិច្ចទាំងឡាយណាដែលមានចែងនៅក្នុងមាត្រា ៤ មាត្រា ៥ នៃព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ត្រូវផ្ទេរជូនទៅអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ជាអ្នកអនុវត្ត និង ទទួលខុសត្រូវជំនួសវិញ ។ ការទទួលខុសត្រូវក្នុងការកំទេចគ្រាប់មីនដូចមានចែងខាងលើ គឺជាបន្ទុករបស់ ម.ស.ម.ក. ។

**មាត្រា ៤ :**

ម.ស.ម.ក. អាចចែករំលែកបច្ចេកទេស និង ការពិសោធន៍របស់ខ្លួន ទៅអោយប្រទេសទាំងឡាយណា ៗ

ដែលមានបញ្ហាមីន ។

មាត្រា ៥ :

ម.ស.ម.ក. ត្រូវអនុវត្តកម្មវិធីដូចតទៅ :

ក. ការយល់ដឹងអំពីគ្រោះថ្នាក់មីន

ខ. ពតិមាន និង ការស្រាវជ្រាវអំពីចំការមីន

គ. ការបោសសំអាតមីន រួមបញ្ចូលទាំងការកំទេចគ្រឿងផ្ទុះចោល

ឃ. ការហ្វឹកហ្វឺនក្នុងសកម្មភាពមីន

ម.ស.ម.ក. ត្រូវចាត់វិធានការដើម្បីធានាសុវត្ថិភាពកំរិតខ្ពស់បំផុត អោយដល់បុគ្គលិកទាំងអស់របស់ខ្លួន ។

មាត្រា ៦ :

កម្មវិធីខាងលើ ត្រូវអនុវត្តក្នុងគោលបំណងសន្តិភាពតែប៉ុណ្ណោះ និង ត្រូវប្រព្រឹត្តទៅតាមលំដាប់អាទិភាពដូចតទៅ :

ក. បំរើគោលដៅមនុស្សធម៌ នៅតាមតំបន់ដែលមានអត្រានៃការគ្រោះដោយសារគ្រាប់មីនខ្ពស់

ខ. បំរើគោលដៅសេដ្ឋកិច្ច ដើម្បីជួយពង្រីកកសិកម្ម ជួយស្តារ ឬកសាងជាតិឡើងវិញ ឬដើម្បីអនុវត្តគំរោងអភិវឌ្ឍន៍ ។

## ជំពូកទី ៣
## ការគ្រប់គ្រងមជ្ឈមណ្ឌល

មាត្រា ៧ :

ម.ស.ម.ក. មានក្រុមប្រឹក្សាភិបាលមួយ និង អង្គភាពប្រតិបត្តិមួយ ។

## ជំពូកទី ៤
## ក្រុមប្រឹក្សាភិបាល

មាត្រា ៨ :

ក្រុមប្រឹក្សាភិបាល ម.ស.ម.ក. មានសមាជិក ៧ រូប ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវបានតែងតាំងឡើងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល ។ល។

**មាត្រា ៩ :**

ក្រុមប្រឹក្សាភិបាលត្រូវមានប្រធានមួយ (១) រូប អនុប្រធានមួយ (១) រូប និង សមាជិកប្រាំ (៥) រូប ។ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានជាស្វ័យប្រវត្តិជាប្រធាននៃក្រុមប្រឹក្សាភិបាល ។ ក្នុងករណីដែលនាយករដ្ឋមន្ត្រីមិនអាចបំពេញមុខនាទីនេះដោយផ្ទាល់បាន នាយករដ្ឋមន្ត្រីអាចទូលស្នើព្រះមហាក្សត្រ សុំតែងតាំងឥស្សរជនមួយរូប ជាប្រធាននៃក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធ ។ ប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធជាតំណាង ម.ស.ម.ក. ។

**មាត្រា ១០ :**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវបានជ្រើសតាំងក្នុងចំណោមឥស្សរជន និង អ្នកជំនាញ ។ តំណាងជាប់ឆ្នោតម្នាក់នៃអង្គភាពប្រតិបត្តិរបស់ ម.ស.ម.ក. ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាលដោយស្វ័យប្រវត្តិ ។ លើកលែងតែនាយករដ្ឋមន្ត្រី សមាជិកអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន មិនត្រូវបានជ្រើសតាំងជាសមាជិកនៃក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ឡើយ ។

**មាត្រា ១១ :**

ក្នុងករណីប្រធានក្រុមប្រឹក្សាភិបាលអវត្តមាន ប្រធានក្រុមប្រឹក្សាភិបាលត្រូវប្រគល់សិទ្ធិអោយអនុប្រធានក្រុមប្រឹក្សាភិបាល ទទួលបន្ទុកជាប្រធានក្រុមប្រឹក្សាភិបាលផ្ទេរសិទ្ធស្តីទី ។

**មាត្រា ១២ :**

ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ អាចចូលរួមក្នុងសម័យប្រជុំក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកសង្កេតការណ៍ ។ អ្នកសង្កេតការណ៍នៃភ្នាក់ងារផ្តល់ហិរញ្ញវត្ថុនេះ មិនត្រូវមានចំនួនលើសពីពីរនាក់ទេ ។

**មាត្រា ១៣ :**

ប្រទេសផ្តល់ជំនួយ អាចចូលរួមក្នុងសម័យប្រជុំក្រុមប្រឹក្សាភិបាលក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

**មាត្រា ១៤ :**

ក្រុមប្រឹក្សាភិបាលមានអាណត្តិបីឆ្នាំ ហើយសមាជិកនៃក្រុមប្រឹក្សាភិបាលនេះ អាចត្រូវបានតែងតាំងជាថ្មីឡើងវិញបាន ។/.

**មាត្រា ១៥ :**

ក្រុមប្រឹក្សាភិបាលត្រូវបើកកិច្ចប្រជុំសាមញ្ញមួយដងក្នុងមួយត្រីមាស ហើយនិងកិច្ចប្រជុំប្រចាំឆ្នាំមួយនៅដំណាច់ឆ្នាំសារពើពន្ធ ។ ប្រធាន ឬ សមាជិកភាគច្រើននៃក្រុមប្រឹក្សាភិបាលអាចកោះការប្រជុំជាវិសាមញ្ញបាន ។

**មាត្រា ១៦ :**

ការប្រជុំក្រុមប្រឹក្សាភិបាលនឹងយកជាការបាន លុះត្រាតែមានសមាជិកភាគច្រើនដាច់ខាតចូលរួម ។ ប្រសិនបើពុំមានសមាជិកភាគច្រើនដាច់ខាតមកចូលរួមប្រជុំទេ ប្រធានត្រូវកោះអញ្ជើញសមាជិកទាំងអស់ជាថ្មីម្តងទៀតមកប្រជុំ ហើយសមាជិកដែលមានវត្តមានតាមការអញ្ជើញនេះ នឹងយកជាបានការដើម្បីធ្វើការប្រជុំ ។ សមាជិកក្រុមប្រឹក្សាភិបាលត្រូវចូលរួមប្រជុំដោយផ្ទាល់ ។

**មាត្រា ១៧ :**

សមាជិកម្នាក់ៗត្រូវមានសិទ្ធិបញ្ចេញសម្លេងតែមួយគត់ ។ សេចក្តីសំរេចនឹងយកជាការបាន បើមានសម្លេងសមាជិកអង្គប្រជុំភាគច្រើនគាំទ្រ ។ នៅពេលដែលមានសមភាពរវាងសម្លេងគាំទ្រ និងសម្លេងមិនគាំទ្រ ប្រធានត្រូវធ្វើសេចក្តីសំរេចជាចុងក្រោយ ។

**មាត្រា ១៨ :**

ក្រុមប្រឹក្សាភិបាលត្រូវមានបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់របៀបរបបធ្វើការងាររបស់ក្រុមប្រឹក្សាភិបាល និង បែងចែកភារកិច្ចទទួលខុសត្រូវដល់សមាជិកនានា ។

**មាត្រា ១៩ :**

ក្រុមប្រឹក្សាភិបាលមានមុខងារដូចតទៅ :

ក. កំណត់យុទ្ធសាស្ត្រ និង នយោបាយដឹកនាំរបស់ ម.ស.ម.ក. ដោយផ្អែកលើមូលដ្ឋាននៃសំណើដែល ម.ស.ម.ក. បានស្នើឡើងដោយខ្លួនឯងទៅតាមជំនាញ និង បទពិសោធន៍របស់សមាជិកក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ។

ខ. តាមដានសកម្មភាពរបស់ ម.ស.ម.ក. ហើយនិងផ្តល់ការណែនាំដើម្បីញ៉ាំងអោយកិច្ចប្រតិបត្តិការ ម.ស.ម.ក. ប្រព្រឹត្តទៅស្របនឹងគោលដៅ ហើយនិងសកម្មភាពរបស់មជ្ឈមណ្ឌល ដែលមានចែងក្នុងជំពូកទី ២ ។

គ. អនុម័តលើកម្មវិធី ផែនការការងារ ថវិកា គណនេយ្យ ហើយនិងរបាយការណ៍របស់ ម.ស.ម.ក. ។ ...

ឃ. អនុម័តបទបញ្ជាផ្ទៃក្នុង និង ការរៀបចំរចនាសម្ព័ន្ធរបស់ ម.ស.ម.ក. ។

ង. អនុម័តសេចក្ដីសំរេចលើបញ្ហាសំខាន់ៗទាំងឡាយឯទៀតដែលទាក់ទងនឹង ម.ស.ម.ក. ។

ច. ធ្វើសំណើទៅនាយករដ្ឋមន្ត្រី សុំតែងតាំងអគ្គនាយក ម.ស.ម.ក. និង ក្នុងករណីចាំបាច់ លើក អនុសាសន៍ជូននាយករដ្ឋមន្ត្រី សុំធ្វើការផ្លាស់ប្ដូរអគ្គនាយក ម.ស.ម.ក ដោយផ្អែកតាមលទ្ធផល នៃការវាយតំលៃលើការអនុវត្តន៍ការងាររបស់អគ្គនាយក ។

**មាត្រា ២០:**

សេចក្ដីសំរេចរបស់ក្រុមប្រឹក្សាភិបាល នឹងចូលជាធរមានប្រាំពីរថ្ងៃក្រោយដែលបានអនុម័តរួច លើកលែង តែការងារខ្លះដែលត្រូវចាត់ការជាចាំបាច់ និង បន្ទាន់ ។

**មាត្រា ២១ :**

តំណាងមកពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ ឥស្សរជនមួយរូប ដែលតែងតាំងឡើងដោយរាជរដ្ឋាភិបាល ត្រូវទទួលតំណែងជាហិរញ្ញិកនៃក្រុមប្រឹក្សាភិបាល និង មានមុខងារជាអាទិ៍ដូចតទៅ :

ក. ផ្ដល់យោបល់លើការរៀបចំច្បាប់ទាំងឡាយខាងផ្នែកហិរញ្ញវត្ថុសំរាប់ដាក់ជូនក្រុមប្រឹក្សាភិបាល ពិនិត្យ និង អនុម័ត ។

ខ. សំរបសំរួលអោយមានការអនុវត្តន៍ហិរញ្ញកិច្ច សមស្របទៅតាមច្បាប់ជាធរមាន ។

គ. ពិនិត្យ និង ផ្ដល់យោបល់លើសេចក្ដីរាយការណ៍អំពីចំណូល-ចំណាយប្រចាំត្រីមាស របស់ ម.ស.ម.ក. ជូនក្រុមប្រឹក្សាភិបាល ។

ឃ. គ្រប់គ្រងរាល់ហិរញ្ញកិច្ច និង គណនេយ្យរបស់ក្រុមប្រឹក្សាភិបាល ប្រកបដោយប្រសិទ្ធភាព និង តម្លាភាពខ្ពស់ ។

## ជំពូកទី ៥
## អង្គភាពប្រតិបត្តិ

**មាត្រា ២២:**

អង្គភាពប្រតិបត្តិមាន អគ្គនាយកមួយរូប អគ្គនាយករងមួយរូប នាយកដ្ឋាន អង្គភាពបច្ចេកទេស និង អង្គភាពដោះមីន ។ ក្នុងករណីចាំបាច់ អគ្គនាយកអាចស្នើទៅក្រុមប្រឹក្សាភិបាល សុំបង្កើត ឬលុបចោល នូវនាយកដ្ឋាន និង/ឬ អង្គភាពដោះមីនបាន ។/.

**មាត្រា ២៣ :**

អង្គភាពប្រតិបត្តិ ត្រូវដឹកនាំដោយអគ្គនាយក ។ អគ្គនាយកត្រូវបានតែងតាំងឡើងដោយព្រះរាជក្រឹត្យ សំរាប់អាណត្តិបីឆ្នាំ តាមសេចក្តីស្នើសុំពីក្រុមប្រឹក្សាភិបាលទៅនាយករដ្ឋមន្ត្រី ។ អគ្គនាយក ជាអគ្គលេខាធិការនៃក្រុមប្រឹក្សាភិបាល ។ អគ្គនាយកអាចត្រូវតែងតាំងជាថ្មីឡើងវិញបាន ។

**មាត្រា ២៤ :**

អគ្គនាយកអាចស្នើការជ្រើសរើសអគ្គនាយករងមួយរូបទៅក្រុមប្រឹក្សាភិបាល ។ អគ្គនាយករងត្រូវតែងតាំងឡើងដោយអនុក្រឹត្យ ។

**មាត្រា ២៥ :**

អគ្គនាយក ម.ស.ម.ក. មានមុខងារជាអាទិ៍ដូចតទៅ :

ក. រៀបចំចាត់ចែង និង គ្រប់គ្រង ម.ស.ម.ក. ទៅតាមព្រះរាជក្រឹត្យនេះ ។

ខ. អនុវត្តគោលនយោបាយដឹកនាំរបស់ក្រុមប្រឹក្សាភិបាល ។

គ. ដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័តនូវកម្មវិធី ផែនការការងារ គំរោងថវិកា គណនេយ្យ ហើយនិងរបាយការណ៍ប្រចាំឆ្នាំរបស់ ម.ស.ម.ក. ។

ឃ.ដាក់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ និង ប្រទេសផ្តល់ជំនួយ នូវសេចក្តីរាយការណ៍ និង របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ ម.ស.ម.ក. ។

ង. ដឹកនាំកិច្ចប្រតិបត្តិការសកម្មភាពកំចាត់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ស្របតាមផែនការការងារ និងកម្មវិធីដែលបានអនុម័តហើយរបស់ ម.ស.ម.ក. ប្រកបដោយប្រសិទ្ធិភាព និងតម្លាភាពខ្ពស់

ច. ចាត់ចែង និង ចេញបញ្ជាចំណាយនានា តាមគំរោងថវិកាដែលបានអនុម័តហើយ និង គ្រប់គ្រងលើរាល់ចំណូល-ចំណាយប្រចាំឆ្នាំរបស់ ម.ស.ម.ក. ។

ឆ. តែងតាំង ដឹកនាំបុគ្គលិក និង តំឡើងឋានន្តរសក្តិរបស់បុគ្គលិក នៃ ម.ស.ម.ក. ហើយនិងដាក់វិន័យទៅតាមបទបញ្ជា ដែលក្រុមប្រឹក្សាភិបាលបានសំរេចយល់ព្រមហើយ ដើម្បីលើកកំពស់ប្រសិទ្ធិភាព សមត្ថភាព និង ការស្មោតស្មុំក្នុងការធ្វើការងារអោយបានកំរិតខ្ពស់ ។

**មាត្រា ២៦ :**

ក្នុងករណីអគ្គនាយកអវត្តមាន អគ្គនាយកត្រូវផ្ទេរសិទ្ធិរបស់ខ្លួនទៅឱ្យអគ្គនាយករង ធ្វើជាអគ្គនាយកស្តីទី ។ល។

## ជំពូកទី ៦
## ការចាត់ចែងហិរញ្ញវត្ថុ

**មាត្រា ២៧:**

ម.ស.ម.ក. ជាស្ថាប័នជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលពុំមានទិសដៅស្វែងរកចំណេញឡើយ ។ ម.ស.ម.ក. ត្រូវមានថវិការបស់ខ្លួនសំរាប់ការរៀបចំ ការប្រព្រឹត្តិទៅ និង សំរាប់កិច្ចប្រតិបត្តិការទាំងឡាយរបស់ខ្លួន ។

**មាត្រា ២៨:**

ម.ស.ម.ក. អាចសុំ អាចទទួល អាចទិញ ឬពុំនោះទេ អាចសុំពីស្ថាប័នរដ្ឋាភិបាល ឬ អន្តររដ្ឋាភិបាល ឬ ពីបុគ្គល ឬក៏ពីក្រុមហ៊ុន ឬក៏ពីស្ថាប័នឯទៀតៗ ដោយអំណោយក្តី ឬក៏ដោយមធ្យោបាយឯទៀតណាក៏ដោយក្តី នូវធនធានទាំងឡាយរាប់ទាំងប្រាក់កាស និង អំណោយដែលមានប្រយោជន៍ ឬដែលត្រូវការចាំបាច់ក្នុងការធ្វើអោយសំរេចគោលដៅរបស់ខ្លួន ។ ម.ស.ម.ក. អាចទិញចលនវត្ថុ ឬអចលនវត្ថុណាដែលចាំបាច់សំរាប់សកម្មភាពរបស់ខ្លួន ។

**មាត្រា ២៩:**

ម.ស.ម.ក. អាចតំរូវអោយរូបវន្តបុគ្គល ក្រុមហ៊ុន ឬស្ថាប័នផ្សេងៗ បង់ថ្លៃលើផលិតផល ឬសេវាដែលខ្លួនផ្តល់អោយ ។ ថ្លៃទាំងនេះមិនត្រូវអោយហួសលើសពីតម្លៃផលិតកម្មឡើយ ។

**មាត្រា ៣០:**

ម.ស.ម.ក. ត្រូវមានបែបបទហិរញ្ញវត្ថុរបស់ខ្លួន ហើយត្រូវដាក់របាយការណ៍ហិរញ្ញវត្ថុអោយបានទៀងទាត់ជូនទៅក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ប្រទេសផ្តល់ជំនួយ និង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ។

**មាត្រា ៣១:**

គណនេយ្យចំណាយ-ចំណូលរបស់ ម.ស.ម.ក. ត្រូវបើកចំហអោយមានការត្រួតពិនិត្យផែកនេរ ពីសំណាក់អង្គការឯករាជ្យណាមួយ តាមសំណើរបស់ភ្នាក់ងារផ្តល់ហិរញ្ញវត្ថុ ឬប្រទេសផ្តល់ជំនួយ ឬអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន ។ សំណើសុំធ្វើការត្រួតពិនិត្យផែកនេរជាផ្លូវការខាងលើនេះ ត្រូវផ្ញើទៅក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ។៚

**មាត្រា ៣២ :**

ម.ស.ម.ក. ត្រូវបានរួចពីពន្ធគយលើទំនិញទាំងឡាយដែលខ្លួនទិញ ឬ ក៏ទទួលជាអំណោយ សំរាប់ការកកើត និង ការប្រព្រឹត្តទៅ ហើយនិងសកម្មភាពរបស់ខ្លួន ។

## ជំពូកទី ៧
## ការជាប់សំណង និង វិវាទ

**មាត្រា ៣៣ :**

បុគ្គលិក និងសមាជិកក្រុមប្រឹក្សាភិបាល ម.ស.ម.ក. នឹងមិនត្រូវជាប់សំណងផ្ទាល់ខ្លួនប្រភេទណាមួយដែលបណ្តាលមកពីការបំពេញមុខងារជាផ្លូវការរបស់ខ្លួនឡើយ ។

**មាត្រា ៣៤ :**

ម.ស.ម.ក. ត្រូវទទួលខុសត្រូវចំពោះករណីតវ៉ាអោយសងសំណងនេះ ទៅតាមច្បាប់ដែលមានជាធរមាន ។

**មាត្រា ៣៥ :**

ម.ស.ម.ក. ចេញមុខការពារ ឬប្តឹងតវ៉ាជំនួសបុគ្គលិក និង សមាជិកក្រុមប្រឹក្សាភិបាល ម.ស.ម.ក. ក្នុងករណីដែលមានវិវាទក្នុងការបំពេញមុខងារជាផ្លូវការរបស់ខ្លួន ។ ម.ស.ម.ក. មានភារកិច្ចចេញមុខការពារ តវ៉ា ឬ ដោះស្រាយការទាមទារ ឬ បណ្តឹងផ្សេងៗទៀត ដែលបណ្តាលមកពី សកម្មភាព ឬកិច្ចប្រតិបត្តិការ នៃ ម.ស.ម.ក. រាប់ទាំងថ្ងៃចំណាយនៃរឿងវិវាទនោះផង ។ នីតិវិធីលំអិត ត្រូវកំណត់ដោយឡែកនៅក្នុងបទបញ្ជាផ្ទៃក្នុង ។

## ជំពូកទី ៨
## ផ្សេងៗ

**មាត្រា ៣៦ :**

ម.ស.ម.ក. ត្រូវស្ថិតនៅជាស្ថាប័នដែលអនុវត្តការងាររហូតដល់ទីបញ្ចប់នៃបេសកកម្មរបស់ខ្លួន និងរហូតដល់ការចាត់ចែងទ្រព្យសម្បត្តិ ការបំពេញកាតព្វកិច្ចនានា និង ការសងបំណុលរបស់ខ្លួន រួចរាល់ និង ចប់សព្វគ្រប់ ។ ការបញ្ចប់បេសកកម្មនៃ ម.ស.ម.ក. ហើយនិងការចាត់ចែងទ្រព្យសម្បត្តិ និងបំណុលរបស់ខ្លួន ត្រូវមានការទទួលយល់ព្រមពីរាជរដ្ឋាភិបាល ។/.

## ជំពូកទី ៩

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧ :**

ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និង ព្រះរាជក្រឹត្យលេខ នស/រកត/០៦៩៩/១៣៨ ចុះថ្ងៃ ទី២១ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការសំរួលខ្លឹមសារនៃព្រះរាជក្រឹត្យស្តីពីការបង្កើតមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជានេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៨ :**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣៩ :**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីពេលឡាយព្រះហស្ថលេខាតទៅ ។៤.៖.

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០១

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ១៦៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែសីហា ឆ្នាំ ២០០១

**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

[illegible] តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦៥

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សំណើរបស់ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា១ : តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ទោ ជាកិច្ចបច្ឆាមរណៈជូនចំពោះសព ឧត្តមសេនីយ៍ត្រី ឆ្លូន ថែម អត្តលេខ០០៣៨០៩ ទីប្រឹក្សា ក្រសួងការពារជាតិ

មាត្រា២ : តម្លើងឋានន្តរសក្តិ ថ្នាក់ឧត្តមសេនីយ៍ត្រី ជាកិច្ចបច្ឆាមរណៈជូនចំពោះសព

១- វរសេនីយ៍ឯក ម៉ាញ យ៉ារិន អត្តលេខ ០០៤៤០៩ អាកាសយានិក AN-24 និងជាមេបញ្ជាការរងកងបោះដឹកជញ្ជូនប្រតិភូជាន់ខ្ពស់

២- វរសេនីយ៍ឯក យ៉ាត ម្លួន អត្តលេខ ០០០៣៥០ នាយសេនាធិការរង យោធភូមិភាគទី ១

មាត្រា៣ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បាននាយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា

**ហ៊ុន សែន**

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
សហរដ្ឋមន្ត្រីក្រសួងការពារជាតិ
ព្រះហស្តលេខា និង ហត្ថលេខា
ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរត្ន ទៀ បាញ់

ចម្លងចេញពីច្បាប់ដើម ច.ល
ដើម្បីចម្លងជូន
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០១
អគ្គលេខាធិការរាជរដ្ឋាភិបាល
សោម គាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៨០១/២៦៦

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលបានត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៨ ៣០ ៣៤ ៥១ ៩០ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់មាត្រា ១១៩ ថ្មី និង ១៥៧ ថ្មី នៃរដ្ឋធម្មនុញ្ញ និងប្រការ ៧៨ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា
- បានទ្រង់យល់សំណើរបស់សម្តេច ហ៊ុន សែន ប្រធានស្តីទីគណបក្សប្រជាជនកម្ពុជា ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចក្រុមឃុន ប្រធានព្រឹទ្ធសភាស្តីទី ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១

ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **តូច សារ៉ក់** ជាសមាជិកព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា សំរាប់នីតិកាលទី ១ ជំនួស ឯកឧត្តម **ប៊ុល ណារ៉ល់** ដែលបានទទួលមរណភាព ។

**មាត្រា ២ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៦៧៥ ច.ល

ចំលងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០១

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ០៤២/០០៥/២០០១

ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

**សេចក្តីសំរេច**

លេខ : ០៤៣/០០៥/២០០១ កបធ.ច

ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

**ក្រុមប្រឹក្សាធម្មនុញ្ញ**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញលិខិតប្រធានរដ្ឋសភាលេខ ៤៨៩ រ.ស ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១ ស្នើឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃការធ្វើនិយតកម្មមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ហើយព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់នៅថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ដោយយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់ទាំងស្រុងគ្មានកែប្រែអ្វីឡើយ ហើយដែលក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០១

-បានឃើញសេចក្តីសំរេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលេខ ០៤០ / ០០២ / ២០០១ កបធ.ច ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១ បានប្រកាសថា " *ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* " ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែបទបញ្ញត្តិទាំងឡាយដែលបានចែងថា " *... ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទីបី* " ដែលជាទោសសម្លាប់ក្នុងមាត្រា ២០៩ . ៥០០ . ៥០៦ និង ៥០៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ដែលត្រូវបានចង្អុលក្នុងមាត្រា ៣ នៃច្បាប់នេះ

2

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

-យល់ឃើញថា រដ្ឋសភា និងព្រឹទ្ធសភា បានអនុម័តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុង មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យអនុម័តការធ្វើវិសោធនកម្មមាត្រា ៣ នៃច្បាប់នេះ

-យល់ឃើញថា រដ្ឋសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទដែលមានចែងក្នុងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌទី ២ ក្នុងការបញ្ជូនមកឱ្យក្រុមប្រឹក្សាធម្មនុញ្ញ ពិនិត្យមុននឹងច្បាប់នេះ ត្រូវបានប្រកាសឱ្យប្រើ

-យល់ឃើញថា ការធ្វើវិសោធនកម្មមាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រ-ជាធិបតេយ្យ បានឆ្លើយតបជាវិជ្ជមានទៅនឹងការកត់សំគាល់របស់ក្រុមប្រឹក្សាធម្មនុញ្ញក្នុងសេចក្តី-សំរេចលេខ ០៤០/០០២/២០០១ កបធ.ក ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០១

**សំរេច**

**មាត្រា ១** - ផ្អែកតាមមូលបទខាងលើ មាត្រា ៣ នៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុង តុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជា-ធិបតេយ្យ ដែលរដ្ឋសភាបានអនុម័តយល់ព្រមធ្វើវិសោធនកម្ម កាលពីថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានពិនិត្យ ចប់សព្វគ្រប់កាលពីថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី ១ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** - សេចក្តីសំរេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ នាសម័យប្រជុំពេញ អង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាសេចក្តីសំរេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្ត ទៅលើអំណាចទាំងអស់ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ និងត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**បិន ឈិន**

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៦៣.អនក្រ/បក

## អនុក្រឹត្យ

ស្តីពី

## ការចេញផ្សាយក្រដាសប្រាក់ប្រភេទ ១០០ រៀល គំរូថ្មី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

## សំរេច

**មាត្រា ១ :** អនុញ្ញាតអោយចេញផ្សាយ ធ្វើចរាចរនិងប្រើប្រាស់ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា នូវក្រដាសប្រាក់ ១០០ រៀល គំរូថ្មី ទន្ទឹមនឹងប្រភេទប្រាក់ដែលមានចេញផ្សាយរួចមកហើយ ។

**មាត្រា ២ :** ធនាគារជាតិនៃកម្ពុជា មានភារកិច្ចចេញសេចក្តីប្រកាសមួយ ដើម្បីផ្សព្វផ្សាយពីលក្ខណៈសំគាល់ នៃក្រដាសប្រាក់គំរូថ្មីនេះ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ននិងអភិបាលខេត្តក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>ចម្លងជូន</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៤ អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

ការប្រើប្រាស់គណនី

ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ

៙☆៙

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០០ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ២០០១
- បានឃើញអនុក្រឹត្យលេខ ៣៨ អនក្រ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៥ ស្តីពីបែបបទ នៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពី ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំ រេ ច

**មាត្រា ១** : អនុញ្ញាតអោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រើប្រាស់គណនី " ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ " ដែលត្រូវបានបង្កើតឡើង តាមមាត្រា ៨៣ នៃច្បាប់ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ លើមុខសញ្ញាចំណាយសំរាប់ផ្តល់ជូនទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីអោយសាលាក្រុងភ្នំពេញធ្វើការទូទាត់ក្នុងការទិញដីរៀបចំហេដ្ឋារចនាសម្ព័ន្ធអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល និង ធ្វើអោយបរិដ្ឋានល្អប្រសើរនៅតំបន់អភិវឌ្ឍន៍ថ្មី ភូមិទួលជង្រុក សង្កាត់ត្រពាំងក្រសាំង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានទឹកប្រាក់ សរុបចំនួន USD 60.000,00 ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ និង ប្រធានស្ថាប័នដែលពាក់ព័ន្ធ មានភារកិច្ចអនុវត្តសនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចំលងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- កាលប្បវត្តិ-ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

************

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ២១០ លានរៀល ( ពីររយដប់លានរៀលគត់ ) ពីជំពូក ៣០ (អន្តរាគមន៍ក្នុងវិស័យសេដ្ឋកិច្ច ) មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការផ្គត់ផ្គង់តូច ) របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយនៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង អនុកថាខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់រៀបចំប្រជុំប្រចាំឆ្នាំលើកទី ៣៨ និង ប្រជុំគណៈកម្មាធិការដឹកនាំលើកទី ៣៨ នៃគណៈកម្មាធិការទំនាក់ទំនងកម្មវិធីវិទ្យាសាស្ត្រ ផែនដី នៅតំបន់អាស៊ីបូព៌ា និង អាស៊ីអាគ្នេយ៍ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែសីហា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

# ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រង សកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥៩៩/០៣ ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦១ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការតែងតាំងសមាសភាពអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០១/២៦៤ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១ ស្តីពីមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សំរេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

មាត្រា ១ :

អនុក្រឹត្យនេះកំណត់ការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន និង កំណត់នូវតួនាទី និង ភារកិច្ចអគ្គលេខាធិការដ្ឋាន និង នាយកដ្ឋាននានាដែលនៅចំណុះ ។ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន អាចហៅថា "អាជ្ញាធរសកម្មភាពមីនកម្ពុជា" ឬ "អាជ្ញាធរមីន" ឬ ហៅជាអក្សរកាត់ភាសាអង់គ្លេសថា "ស៊ី.អ៊ឹម.អេ.អេ" (CMAA) នៅក្នុងអនុក្រឹត្យនេះហៅថា "អាជ្ញាធរ" ។

## ជំពូកទី ២
## និយមន័យ

មាត្រា ២ :

២.១. *បណ្ណទទួលស្គាល់* : គឺជានីតិវិធីដែលអង្គការប្រតិបត្តិករសកម្មភាពមីនទាំងអស់ ត្រូវបានការទទួលស្គាល់ជាផ្លូវការថាមានសមត្ថភាពក្នុងការរៀបចំផែនការ គ្រប់គ្រង និងធ្វើប្រតិបត្តិការសកម្មភាពមីន ប្រកបដោយសុវត្ថិភាព សុក្រឹត្យភាព និង ប្រសិទ្ធិភាពខ្ពស់ ។

២.២. *ម្ចាស់ជំនួយ* : សំដៅលើអង្គការ ក្រុមហ៊ុន សមាគម ស្ថាបនិក ក្នុងប្រទេស និង អន្តរជាតិ ព្រមទាំងបណ្តាប្រទេសដែលបានសន្យាផ្តល់ជំនួយបច្ចេកទេស ឬថវិកា ដោយផ្ទាល់ ឬដោយប្រយោលដល់សកម្មភាពទាំងឡាយ ទាំងការកំចាត់មីន និង គំរោងអភិវឌ្ឍន៏ផ្សេងៗ មានហេដ្ឋារចនាសម្ព័ន្ធ ការអប់រំ ការថែទាំសុខភាព ។ល។ ក្នុងប្រទេសកម្ពុជា ។

២.៣. *អចលនទ្រព្យ* : សំដៅលើទ្រព្យសម្បត្តិសំរាប់ប្រើប្រាស់បានរយៈពេលយូរ មានជាអាទិ៍ អាគារ សំភារៈបរិក្ខារ ដីធ្លី ដែលមានវត្តមានជារូបីយ ហើយដែលត្រូវប្រើប្រាស់ក្នុងប្រតិបត្តិការដោយអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ។

២.៤. *អាជ្ញាប័ណ្ណ* : គឺជាវិញ្ញាបនប័ត្រដែលចេញឱ្យដោយ "អាជ្ញាធរ" ចំពោះអង្គការប្រតិបត្តិករទាំងឡាយដែលមានសមត្ថភាពអាចបំរើសេវាកម្មលើកិច្ចប្រតិបត្តិការ ដូចជាកម្មវិធីយល់ដឹងពីមីន កម្ម

វិធីផ្ទៀងផ្ទាត់ស្រាវជ្រាវចំការមីន កម្មវិធីបោសសំអាតមីន កម្មវិធីហ្វឹកហ្វឺន កម្មវិធីសង្គ្រោះជនពិការដោយសារមីន កម្មវិធីអភិវឌ្ឍន៍បច្ចេកទេសជាដើម ។

២.៥. *អង្គការប្រតិបត្តិករជាតិ និងអន្តរជាតិ* : សំដៅលើអង្គការជាតិ និង អន្តរជាតិ និង បុគ្គលដែលពាក់ព័ន្ធនឹង "សកម្មភាពកំចាត់មីន" ដោយរួមទាំងស្ថាប័នរបស់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល អង្គការសប្បុរសធម៌នានា ក្រុមហ៊ុនពាណិជ្ជកម្ម ក្រុមហ៊ុនឯកជន និង បុគ្គល ។

២.៦. *សកម្មភាពកំចាត់មីន* ឬ *សកម្មភាពមីន* ( មានន័យដូចគ្នា ) : សំដៅលើសកម្មភាពទាំងឡាយដែលនាំទៅដល់ការកាត់បន្ថយនូវឥទ្ធិពលមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលប៉ះពាល់ដល់សេដ្ឋកិច្ច និង បរិយាកាសសង្គម ។ សកម្មភាពទាំងនោះ រួមមាន :

២.៦.១. កម្មវិធីយល់ដឹងអំពីមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ ការអប់រំ និង សកម្មភាពប្រហាក់ប្រហែល

២.៦.២. កម្មវិធីផ្ទៀងផ្ទាត់ស្រាវជ្រាវចំការមីន រួមមានកំរិត ១ កំរិត ២ និង កំរិត ៣ ការស្រាវជ្រាវសកម្មភាពមីន ក៏ដូចជាការអនុវត្តន៍ក្នុងការប្រមូល និងស្រាវជ្រាវទិន្នន័យដែលទាក់ទងដោយផ្ទាល់ទៅនឹងសកម្មភាពមីន

២.៦.៣. ការកំណត់ទីកន្លែង ការដាក់ផ្លាកសញ្ញា ការយកចេញ ការដឹកជញ្ជូន ការរក្សាទុក ការធ្វើឱ្យអស់អនុភាព និង ការកំទេចចោលនូវមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះគ្រប់ប្រភេទ ។ សកម្មភាព ក៏មានរាប់បញ្ចូលផងដែរនូវគ្រឿងផ្ទុះប្រភេទដទៃៗទៀត ដែលបង្កការគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ ប៉ុន្តែមិនរាប់បញ្ចូលគ្រឿងរំសេវដែលមិនផ្ទុះ និង ស្ថិតនៅក្រោមការត្រួតពិនិត្យ របស់អាជ្ញាធរពាក់ព័ន្ធ

២.៦.៤. ការទទួលយក ការដឹកជញ្ជូន ការរក្សាទុក ការបែងចែក និង ការប្រើប្រាស់គ្រឿងផ្ទុះសំរាប់កំទេចមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះ

២.៦.៥. កម្មវិធីហ្វឹកហ្វឺនបច្ចេកទេសទាក់ទងនឹងសកម្មភាពខាងលើ

២.៦.៦. កម្មវិធីសង្គ្រោះជនពិការដោយសារមីន

២.៦.៧. កម្មវិធីអភិវឌ្ឍន៍បច្ចេកទេសថ្មីៗ ទាក់ទងទៅនឹងសកម្មភាពខាងលើ ។

២.៧. *យុទ្ធភណ្ឌមិនទាន់ផ្ទុះ* : សំដៅលើគ្រឿងផ្ទុះដែលត្រូវបានបំពាក់ឱ្យដំណើរការ ឬ ជាការដំឡើងសំរាប់ប្រើប្រាស់ ឬ បានប្រើប្រាស់ ។ វាអាចត្រូវបានបាញ់ ទំលាក់ ផ្លោង ឬ ក៏បាញ់ឱ្យខ្ទាតអំបែង

ហើយដែលនៅតែមិនផ្ទុះ ដោយហេតុថាការមិនដំណើរការស្រួល ឬ ក៏ការផលិតមិនបានល្អ ឬ ដោយហេតុផលផ្សេងៗ ។

២.៨. *សង្គ្រោះជនពិការដោយសារមីន* : សំដៅលើការសង្គ្រោះជនរងគ្រោះដែលបណ្ដាលមកពីឧប្បទ្ទវហេតុផ្ទុះមីន និង យុទ្ធភណ្ឌគ្រប់ប្រភេទ ។ កិច្ចសង្គ្រោះនេះ ត្រូវលាតសន្ធឹងចាប់ពីការព្យាបាលតូចតាច រហូតដល់ការស្ដារនាឡើងវិញនូវកាយសម្បទា និង ការឧបត្ថម្ភដល់ក្រុមគ្រួសារទាំងមូល ដើម្បីលើកកំពស់ផ្នែកសេដ្ឋកិច្ចសង្គម ។

## ជំពូកទី ៣

## បេសកកម្ម និង រចនាសម្ព័ន្ធ

មាត្រា ៣ :

"អាជ្ញាធរ" មានបេសកកម្មដឹកនាំ និងគ្រប់គ្រងលើវិស័យកិច្ចប្រតិបត្តិការសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងគោលដៅជំរុញចលនាបោសសំអាតមីន ការប្រើប្រាស់ជំនួយ និង ការបែងចែកដីធ្លីដែលបោសសំអាតមីនរួចហើយ អោយមានសុវត្ថិភាព ប្រសិទ្ធភាព និង តម្លាភាព ព្រមទាំងសំរបសំរួលកិច្ចប្រតិបត្តិការរវាងបណ្ដាប្រតិបត្តិករទាំងអស់ ។

មាត្រា ៤ :

"អាជ្ញាធរ" មានភារកិច្ចដូចតទៅ :

៤.១. រៀបចំស្ដង់ដា នីតិវិធី គោលការណ៍បច្ចេកទេស ថវិកា និង បទប្បញ្ញត្តិផ្សេងៗទាក់ទងទៅនឹងការធ្វើផែនការសកម្មភាពមីន និងការគ្រប់គ្រងពត៌មានបច្ចេកទេស

៤.២. រៀបចំផែនការជាតិសកម្មភាពមីន (និងរបាយការណ៍ពាក់ព័ន្ធ និងបន្តបន្ទាប់តាមពេល) រួមមាន :

៤.២.១. រៀបចំផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ នៃសកម្មភាពមីន និង សកម្មភាពទ្រទ្រង់ផ្សេងៗ

៤.២.២. ពិនិត្យ និងជ្រើសរើសគំរោងស្នើ (ដោយផ្អែកលើផែនការសកម្មភាព) ដែលទាក់ទងទៅនឹងបញ្ហាមីន/យុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលភាគីពាក់ព័ន្ធនានាដាក់ជូនមកដើម្បីផ្ញើទៅម្ចាស់ជំនួយ

៤.២.៣. រៀបចំយុទ្ធសាស្ត្រផ្សេងៗ និងឯកសារដទៃទៀតដែលទាក់ទងទៅនឹងសកម្មភាពជាតិក្នុងការគ្រប់គ្រងលើវិស័យសកម្មភាពមីន

៤.៣. សំរបសំរួលរាល់ការងារសកម្មភាពមីន

៤.៤. តាមដាន និង ត្រួតពិនិត្យការងារសកម្មភាពមីន ដើម្បីឱ្យអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិទាំងអស់ អនុវត្តស្របតាមនយោបាយយុទ្ធសាស្ត្រ និង ផែនការរបស់រាជរដ្ឋាភិបាល

៤.៥. គៀងគរប្រភពធនធាន ជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ ទាំងក្នុង និង ក្រៅប្រទេស សំរាប់ដំណើរការសកម្មភាពមីន

៤.៦. បញ្ជាអោយកំទេចចោល :

៤.៦.១. គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស

៤.៦.២. គ្រាប់មីនគ្រប់ប្រភេទប្រឆាំងរថក្រោះ និង ប្រឆាំងយានគ្រប់ប្រភេទ និង គ្រឿងផ្ទុះគ្រប់ប្រភេទ ដែលទុកចោលមិននៅក្រោមការគ្រប់គ្រងរបស់អាជ្ញាធរមានសមត្ថកិច្ច

៤.៦.៣. យុទ្ធភណ្ឌមិនទាន់ផ្ទុះគ្រប់ប្រភេទ

៤.៧. ផ្តល់ កែលំអ ដកហូតប័ណ្ណទទួលស្គាល់ និង អាជ្ញាប័ណ្ណពីអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិនានា ដែលធ្វើសកម្មភាពបោសសំអាតមីន ក្នុងព្រះរាជាណាចក្រកម្ពុជា

៤.៨. គ្រប់គ្រងទិន្នន័យ និង ប្រព័ន្ធពត៌មាននានាដែលពាក់ព័ន្ធ ឬតំរូវការដែលទាមទារដោយ "អាជ្ញាធរ" ក្នុងការបំពេញមុខងាររបស់ខ្លួន

៤.៩. សំរបសំរួលជាមួយម្ចាស់ជំនួយ ភ្នាក់ងារអភិវឌ្ឍន៍ជាតិ-អន្តរជាតិ ស្ថាប័នរដ្ឋនានា និងអាជ្ញាធរពាក់ព័ន្ធ ភ្នាក់ងារឯកជន ដើម្បីធានាឱ្យមានភាពរីកចំរើនជឿនលឿនដល់គំរោងការណ៍ក្នុងប្រទេសកម្ពុជា ហើយដែលត្រូវបាន និង កំពុងអនុវត្តក្នុងបរិយាកាសប្រកបដោយសុវត្ថិភាពកំរិតខ្ពស់

៤.១០.សំរបសំរួលជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងស្ថាប័នរដ្ឋពាក់ព័ន្ធផ្សេងៗ ដើម្បីរៀបចំ និង ត្រួតពិនិត្យគោលនយោបាយ និង គោលការណ៍នានា ស្តីពីការប្រើប្រាស់ដីធ្លីដែលត្រូវបានបោសសំអាតមីន និង យុទ្ធភណ្ឌមិនទាន់ផ្ទុះរួចហើយ

៤.១១.គ្រប់គ្រងការអនុវត្តន៍នូវច្បាប់ ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស និង សន្ធិសញ្ញាអូតាវ៉ាស្តីពីការហាមប្រាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និង ការផ្ទេរមីនប្រឆាំងមនុស្ស ហើយនិងការបំផ្លាញមីនទាំងនោះចោល

៤.១២.តាមដានពិនិត្យ និងផ្តល់ការណែនាំក្នុងការប្រើប្រាស់ថវិកា សម្ភារៈបរិក្ខារ និងធនធានផ្សេងៗ ដែលផ្តល់ដល់អង្គការប្រតិបត្តិករជាតិ និងអន្តរជាតិទាំងអស់ ។ ធនធាននេះ អាចរួមទាំងធនធានឧបត្ថម្ភដោយរាជរដ្ឋាភិបាលកម្ពុជា សហគមន៍ជាតិ-អន្តរជាតិ ក្រុមហ៊ុនឯកជន និង សប្បុរសជននានា ។

មាត្រា ៥ :

"អាជ្ញាធរ" មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ និង មានអង្គភាព ឬ នាយកដ្ឋានមួយចំនួនទៀត តាមការចាំបាច់នៃការបំពេញការងារទូទៅរបស់ "អាជ្ញាធរ" ។

## ជំពូកទី ៤

## អគ្គលេខាធិការ

មាត្រា ៦ :

អគ្គលេខាធិការ មានភារកិច្ចចាំបាច់ដូចតទៅ :

៦.១. គ្រប់គ្រងចាត់ចែង និង ដឹកនាំការងារប្រចាំថ្ងៃរបស់ "អាជ្ញាធរ" និង សំរបសំរួលរាល់ការងារសកម្មភាពកំចាត់មីនរបស់អង្គការប្រតិបត្តិករទាំងអស់ និង សេហាតមន៍ម្ចាស់ជំនួយ ជំនួសមុខឱ្យ "អាជ្ញាធរ" ។ អគ្គលេខាធិការ មានអគ្គលេខាធិការរងពីររូបជាជំនួយការដែលត្រូវតែងតាំងដោយអនុក្រឹត្យ ។ អគ្គលេខាធិការត្រូវរាយការណ៍ជូនអនុប្រធាន "អាជ្ញាធរ" ។

៦.២. រៀបចំការប្រជុំឱ្យបានទៀងទាត់ជាមួយបណ្តាអង្គការប្រតិបត្តិករ ដែលធ្វើប្រតិបត្តិការសកម្មភាពមីន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៦.៣. រៀបចំអង្គប្រជុំអោយបានទៀងទាត់ជាមួយភ្នាក់ងារផ្តល់ជំនួយ ដើម្បីធានានូវគោលនយោបាយសំរបសំរួល និង ពង្រឹងភាពជាដៃគូ ។

៦.៤. ចាត់ចែង និងចេញបញ្ជាចំណាយនានា តាមគំរោងថវិកាដែលបានអនុម័ត ហើយនិងគ្រប់គ្រងលើរាល់ចំណូល-ចំណាយប្រចាំឆ្នាំរបស់ "អាជ្ញាធរ" ។

## ជំពូកទី ៥

## អគ្គលេខាធិការដ្ឋាន

មាត្រា ៧ :

៧.១. អគ្គលេខាធិការដ្ឋានត្រូវស្ថិតក្រោមការដឹកនាំគ្រប់គ្រងរបស់អគ្គលេខាធិការ ។ ដើម្បីធានាឱ្យមានប្រសិទ្ធិភាព និង សុក្រឹត្យភាពការងារខ្ពស់របស់ "អាជ្ញាធរ" អគ្គលេខាធិការដ្ឋាន មាននាយកដ្ឋានចំនួនប្រាំមួយ សំរាប់បំរើការងារតាមមុខងារដូចតទៅ :

៧.១.១. បទប្បញ្ញត្តិ និង នីតិកម្ម

៧.១.២. ផែនការ ត្រួតពិនិត្យ និង គ្រប់គ្រងទិន្នន័យ

៧.១.៣. កិច្ចសង្គ្រោះជនពិការ

៧.១.៤. សំរបសំរួល និង ទំនាក់ទំនងសាធារណៈ

៧.១.៥. រដ្ឋបាល-បុគ្គលិក និង ភស្តុភារ

៧.១.៦. ហិរញ្ញវត្ថុ

៧.២. អគ្គលេខាធិការដ្ឋាន ត្រូវប្រព្រឹត្តទៅតាមបទបញ្ជាផ្ទៃក្នុង ដែលអនុម័តដោយគណៈអចិន្ត្រៃយ៍ "អាជ្ញាធរ" ។

មាត្រា ៨ :

អគ្គលេខាធិការដ្ឋាន ត្រូវមានត្រាមួយដោយឡែករបស់ខ្លួន ។

មាត្រា ៩ :

នាយកដ្ឋាន ដឹកនាំដោយប្រធាននាយកដ្ឋានមួយរូប ព្រមទាំងសហការីមួយចំនួនជាជំនួយការ ។ ប្រធាននាយកដ្ឋានត្រូវតែងតាំងដោយអនុក្រឹត្យ ។

មាត្រា ១០ :

១០.១. បុគ្គលិកដែលបំរើការឱ្យអគ្គលេខាធិការដ្ឋាន មានពីរប្រភេទ : មន្ត្រីរាជការផ្ទេរមកពីក្រសួង ឬ ស្ថាប័នរដ្ឋនានា និង បុគ្គលិកជាប់កិច្ចសន្យា ។ បុគ្គលិកទាំងពីរប្រភេទនេះ ត្រូវឆ្លងកាត់ការប្រលងជ្រើសរើសប្រកបដោយតម្លាភាព និង ប្រសិទ្ធភាពខ្ពស់ ដោយផ្អែកលើសមត្ថភាព ទេព-កោសល្យ និង បទពិសោធន៍ការងារ ។

១០.២. ចំពោះបុគ្គលិកដែលជាមន្ត្រីរាជការ នៃក្រសួង ឬ ស្ថាប័នរដ្ឋនានាដែលមានបំណងចង់មកបំរើការនៅអគ្គលេខាធិការដ្ឋាន ត្រូវឆ្លងកាត់ការប្រលងប្រកួតសមត្ថភាព មុននឹងស្នើសុំផ្ទេរក្រប-ខ័ណ្ឌ និង ភារកិច្ចរបស់ខ្លួន ។

១០.៣. បទបញ្ជាផ្ទៃក្នុងនៃការគ្រប់គ្រងការងារបុគ្គលិក ត្រូវស្ថិតនៅក្នុងលក្ខខ័ណ្ឌការងារដោយឡែក ដែលកំណត់ដោយសេចក្ដីសំរេចរបស់គណៈអចិន្ត្រៃយ៍ "អាជ្ញាធរ" ។

## ជំពូកទី ៦
## នាយកដ្ឋានបទប្បញ្ញត្តិ និង នីតិកម្ម

មាត្រា ១១ :

នាយកដ្ឋានបទប្បញ្ញត្តិ និង នីតិកម្ម មានភារកិច្ចដូចតទៅ :

១១.១. រៀបចំ និង ពិនិត្យឯកសារកិច្ចព្រមព្រៀងសំរាប់ចុះហត្ថលេខារវាង "អាជ្ញាធរ" និង ម្ចាស់ជំនួយ

១១.២. រៀបចំនីតិវិធីនានា និង ដាក់ឱ្យដំណើរការ នូវការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណដល់គ្រប់អង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ភ្នាក់ងារឯកជន ដែលអនុវត្តសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដំណើរការនេះ ត្រូវប្រព្រឹត្តិទៅប្រកបដោយត្រឹមត្រូវ និង មានតម្លាភាព

១១.៣. គ្រប់គ្រងរាល់ការប្រើប្រាស់ ដឹកជញ្ជូន បែងចែក និង ស្តុកទុកនូវគ្រាប់រំសេវ និងគ្រឿងផ្ទុះរបស់ប្រតិបត្តិករសកម្មភាពមីននានា

១១.៤. រៀបចំកិច្ចដំណើរការ ដើម្បីចេញបញ្ជាអោយកំទេចចោលគ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស រថក្រោះ និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដែលរកឃើញដោយរាល់ប្រតិបត្តិករសកម្មភាពមីន ហើយដែលអាជ្ញាធរមានសមត្ថកិច្ចមិនកាន់កាប់ និង មិនប្រើប្រាស់

១១.៥. រៀបចំចេញផ្សាយនូវស្តង់ដាបច្ចេកទេស នីតិវិធី គោលការណ៍ បទប្បញ្ញត្តិនានា ដែលទាក់ទងនឹងសកម្មភាពមីន

១១.៦. រៀបចំ និង ប្រមូលផ្តុំឯកសារ និង អនុសាសន៍នានា សំរាប់ "អាជ្ញាធរ" ធ្វើការដកហូតនូវប័ណ្ណទទួលស្គាល់ពីអង្គការប្រតិបត្តិករជាតិ និងអន្តរជាតិ ដែលធ្វើសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា

១១.៧. ត្រួតពិនិត្យការអនុវត្តន៍ នូវច្បាប់ស្តីពីការហាមប្រាម ការប្រើប្រាស់មីនគ្រប់ប្រភេទប្រឆាំងមនុស្សជាតិ និង សន្ធិសញ្ញាអូតាវ៉ាស្តីពីការហាមប្រាមការប្រើប្រាស់ ការរក្សាទុក ការផលិត និងការផ្ទេរមីនប្រឆាំងមនុស្ស ហើយនិងការបំផ្លាញមីនទាំងនោះចោល ។

## ជំពូកទី ៧
## នាយកដ្ឋានផែនការ ត្រួតពិនិត្យ និង គ្រប់គ្រងទិន្នន័យ

មាត្រា ១២ :

នាយកដ្ឋានផែនការ ត្រួតពិនិត្យ និង គ្រប់គ្រងទិន្នន័យមានភារកិច្ចដូចតទៅ :

១២.១. រៀបចំស្តង់ដាបច្ចេកទេស នីតិវិធី គោលការណ៍ ថវិកា និង បទប្បញ្ញត្តិទាំងឡាយដែលទាក់ទង ទៅនឹងការធ្វើផែនការសកម្មភាពមីន និង ការគ្រប់គ្រងពត៌មានបច្ចេកទេស

១២.២. រៀបចំផែនការជាតិសកម្មភាពមីន (របាយការណ៍ពាក់ព័ន្ធ និងជាបន្តបន្ទាប់តាមពេល) រួមមាន:

១២.២.១. រៀបចំផែនការយុទ្ធសាស្ត្រ ៥ ឆ្នាំ នៃសកម្មភាពមីន និង សកម្មភាពទ្រទ្រង់ផ្សេងៗ

១២.២.២. ពិនិត្យ និងជ្រើសរើសគំរោងស្នើ(ដោយផ្អែកលើផែនការសកម្មភាព) ដែលទាក់ទង ទៅនឹងបញ្ហាមីន/យុទ្ធភណ្ឌមិនទាន់ផ្ទុះដែលភាគីពាក់ព័ន្ធនានាដាក់ជូនមកដើម្បីផ្ញើ ទៅម្ចាស់ជំនួយ

១២.២.៣. រៀបចំយុទ្ធសាស្ត្រផ្សេងៗ និងឯកសារប្រហាក់ប្រហែលដទៃទៀតដែលទាក់ទងទៅ នឹងសកម្មភាពជាតិក្នុងការគ្រប់គ្រងលើវិស័យសកម្មភាពមីន

១២.៣. ត្រួតពិនិត្យរាល់ប្រតិបត្តិការសកម្មភាពមីន ដើម្បីធានាឱ្យការអនុវត្តន៍ប្រព្រឹត្តិទៅតាមផែនការ យុទ្ធសាស្ត្ររបស់ជាតិ និង តាមស្តង់ដាជាតិ និង អន្តរជាតិ ស្តីពីសកម្មភាពមីន

១២.៤. គ្រប់គ្រង និង រៀបចំមូលដ្ឋានទិន្នន័យប្រមូលផ្តុំនូវរាល់ឯកសារទាក់ទងនឹងសកម្មភាពមីន ដែល បានចុះបញ្ជី និង រក្សាទុក

១២.៥. សហការជាមួយភ្នាក់ងារបោសសំអាតមីនទាំងឡាយ ដើម្បីធានាដំណើរការប្រកបដោយគុណ ភាពនូវការផ្លាស់ប្តូរពត៌មានទាំងក្នុង និងក្រៅប្រទេស និង ត្រួតពិនិត្យទៅតាមផែនការជាតិ ស្តីពីសកម្មភាពមីន

១២.៦. ជួយក្នុងកិច្ចសំរបសំរួលជាមួយម្ចាស់ជំនួយ ភ្នាក់ងារអភិវឌ្ឍន៍ជាតិ និង អន្តរជាតិ ប្រទេសនានា ស្ថាប័នរដ្ឋ និង អាជ្ញាធរពាក់ព័ន្ធ ភ្នាក់ងារឯកជន ដើម្បីរៀបចំផែនការសកម្មភាពជាយុទ្ធសាស្ត្រ ធានាឱ្យមានភាពរីកចំរើនជឿនលឿនដល់គំរោងការណ៍ក្នុងប្រទេសកម្ពុជា ហើយដែលត្រូវបាន និង កំពុងអនុវត្តក្នុងបរិយាកាសប្រកបដោយសុវត្ថិភាពក៏រិតខ្ពស់ ។

## ជំពូកទី ៨

## នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន

មាត្រា ១៣ :

នាយកដ្ឋានសង្គ្រោះជនពិការដោយសារមីន មានភារកិច្ចដូចតទៅ :

១៣.១. តាមដានការងារសង្គ្រោះជនរងគ្រោះដោយសារមីនជាមួយភ្នាក់ងារពាក់ព័ន្ធផ្សេងៗ មានក្រសួង

សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ និង ស្ថាប័នជាតិ ក៏ដូចជាអន្តរជាតិនានា ដែលមានការពាក់ព័ន្ធ ។ ការគ្រប់គ្រង ការសំរបសំរួល និង ការឃ្លាំមើលលើកិច្ចសង្គ្រោះជនពិការដោយសារមីនភាគច្រើន គឺជាការទទួលខុសត្រូវរបស់អង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ និង អង្គការពាក់ព័ន្ធនានា ។ អង្គការទាំងនោះ ត្រូវផ្តល់ជូន "អាជ្ញាធរ" នូវផែនការយុទ្ធសាស្ត្រនៃសកម្មភាពការងារ និងរបាយការណ៍រីកចំរើន ស្តីពីសកម្មភាពសង្គ្រោះជនពិការដោយសារមីន

១៣.២. ធ្វើការទំនាក់ទំនងជាមួយភ្នាក់ងារ និង អង្គការពាក់ព័ន្ធនានា ដើម្បីស្រង់យកពត៌មានស្តីពីស្ថិតិ និង អត្រាគ្រោះថ្នាក់ និង សេវាកម្មពាក់ព័ន្ធនានា

១៣.៣. ទទួលរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ ពីអង្គការជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធទៅនឹងកិច្ចសង្គ្រោះជនពិការដោយសារមីន

១៣.៤. ធ្វើសេចក្តីរាយការណ៍រីកចំរើនប្រចាំខែ ត្រីមាស ឆមាស និង ឆ្នាំ ស្តីពីសកម្មភាពសង្គ្រោះជនពិការដោយសារមីន ជូនអគ្គលេខាធិការ ។

## ជំពូកទី ៩

## នាយកដ្ឋានសំរបសំរួល និង ទំនាក់ទំនងសាធារណៈ

**មាត្រា ១៤ :**

នាយកដ្ឋានសំរបសំរួល និង ទំនាក់ទំនងសាធារណៈ មានភារកិច្ចដូចតទៅ :

១៤.១. រៀបចំតាក់តែងឯកសារពត៌មាន ការបោះពុម្ពផ្សាយ ជាពិសេសបោះពុម្ពផ្សាយសកម្មភាពរបស់ "អាជ្ញាធរ" និងរៀបចំប្រព័ន្ធទំនាក់ទំនងដែលទាក់ទងនឹងសកម្មភាពមីនក្នុងព្រះរាជាណាចក្រកម្ពុជា

១៤.២. ធ្វើទំនាក់ទំនងជាមួយភ្នាក់ងារពត៌មានជាតិ និង អន្តរជាតិ

១៤.៣. សំរបសំរួលជាមួយអង្គការជាតិ-អន្តរជាតិ និង រៀបចំចាត់ចែងដំណើរទស្សនៈកិច្ចនានារបស់ភ្ញៀវជាតិ-អន្តរជាតិ

១៤.៤. រៀបចំរបាយការណ៍នានាដាក់ជូនម្ចាស់ជំនួយ

## ជំពូកទី ១០
## នាយកដ្ឋានរដ្ឋបាល-បុគ្គលិក និង ភស្តុភារ

**មាត្រា ១៥ :**

នាយកដ្ឋានរដ្ឋបាល-បុគ្គលិក និង ភស្តុភារ មានភារកិច្ចដូចតទៅ :

១៥.១. រៀបចំចាត់ចែងភស្តុភារ និង ការទិញសំភារៈ

១៥.២. រៀបចំតាក់តែង និង តាមដានការអនុវត្តន៍បទបញ្ជាផ្ទៃក្នុង និង បទប្បញ្ញត្តិផ្សេងៗ

១៥.៣. រៀបចំលិខិតបទដ្ឋាន ទំនាក់ទំនងជាមួយអង្គការជាតិ និង អន្តរជាតិ

១៥.៤. គ្រប់គ្រងរាល់លិខិតបទដ្ឋាន និង ឯកសារទិន្នន័យបុគ្គលិក

១៥.៥. តំកល់ ត្រួតពិនិត្យ និង ចុះបញ្ជីនូវរាល់ឯកសារចេញ-ចូល

១៥.៦. រៀបចំ និង ធ្វើការជ្រើសរើសបុគ្គលិក ពាមលក្ខណៈវិនិច្ឆ័យប្រកបដោយតម្លាភាព និងអនុលោម ទៅតាមច្បាប់ និង បទប្បញ្ញត្តិនានារបស់រាជរដ្ឋាភិបាល

១៥.៧. សំរបសំរួល ទាក់ទងជាមួយអង្គការប្រតិបត្តិករសកម្មភាពមីនទាំងអស់លើការងារភស្តុភារ

## ជំពូកទី ១១
## នាយកដ្ឋានហិរញ្ញវត្ថុ

**មាត្រា ១៦ :**

នាយកដ្ឋានហិរញ្ញវត្ថុ មានភារកិច្ចដូចតទៅ :

១៦.១. ត្រួតពិនិត្យ និង ផ្តល់ការណែនាំ ក្នុងការប្រើប្រាស់ថវិកា និង សម្ភារៈបរិក្ខារ ដែលផ្តល់ដោយជំនួយរាជរដ្ឋាភិបាល និង សហគមន៍ជាតិ-អន្តរជាតិ ដល់អង្គការប្រតិបត្តិករសកម្មភាពមីននានា

១៦.២. គ្រប់គ្រងចាត់ចែងហិរញ្ញវត្ថុ និង គណនេយ្យ

១៦.៣. រៀបចំគំរោងថវិកា

១៦.៤. រៀបចំ និង ត្រួតពិនិត្យបទប្បញ្ញត្តិហិរញ្ញវត្ថុនៃអង្គការប្រតិបត្តិករសកម្មភាពមីនទាំងអស់

១៦.៥. អនុម័តលើការចំណាយសាច់ប្រាក់ ដោយមានការអនុញ្ញាតិពីអគ្គលេខាធិការ

១៦.៦. រៀបចំ និង បញ្ជាក់និយ័តភាពគណនេយ្យប្រចាំឆមាស និង ប្រចាំឆ្នាំ

១៦.៧. ធ្វើសេចក្តីរាយការណ៍ចំណូល-ចំណាយ និងស្ថានភាពហិរញ្ញវត្ថុរៀងរាល់ខែជូនអគ្គលេខាធិការ ។

## ជំពូកទី ១២
## យន្តការត្រួតពិនិត្យបច្ចេកទេស និង បទបញ្ញត្តិ

**មាត្រា ១៧ :**

អង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យផ្នែកបច្ចេកទេសរបស់អគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" ។

**មាត្រា ១៨ :**

រាល់បណ្តាអង្គការប្រតិបត្តិករ ដែលមានបំណងចង់ធ្វើប្រតិបត្តិការសកម្មភាពមីន ក្នុងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវសុំប័ណ្ណទទួលស្គាល់ និង អាជ្ញាប័ណ្ណ អនុញ្ញាតពី "អាជ្ញាធរ" ។ នីតិវិធីសំរាប់ផ្តល់ប័ណ្ណទទួលស្គាល់ និង អាជ្ញាប័ណ្ណ នឹងមានចែងលំអិតនៅក្នុងគោលនយោបាយដាច់ដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ។

**មាត្រា ១៩ :**

អគ្គលេខាធិការដ្ឋាន ត្រូវបង្កើតឱ្យមានក្រុមពិគ្រោះយោបល់បច្ចេកទេសសកម្មភាពមីនមួយ ។ ក្រុមនេះត្រូវមានតំណាងអ្នកឯកទេសមកពីអង្គការប្រតិបត្តិករជាតិ-អន្តរជាតិ និង ក្រសួងពាក់ព័ន្ធនានា ។

**មាត្រា ២០ :**

មន្ត្រីអគ្គលេខាធិការដ្ឋានត្រូវចុះឱ្យបានទៀងទាត់ ដើម្បីពិនិត្យមើលការអនុវត្តន៍នៃកិច្ចប្រតិបត្តិការបោសសំអាតមីន ដើម្បីធានានូវសុវត្ថិភាព និង ប្រសិទ្ធភាព ។ នីតិវិធីត្រួតពិនិត្យ នឹង វាយតំលៃ នឹងត្រូវចែងលំអិតក្នុងគោលនយោបាយដោយឡែកដែលចេញដោយ "អាជ្ញាធរ" និងមានគោលការណ៍ណែនាំដូចតទៅ :

២០.១. អគ្គលេខាធិការដ្ឋាន ត្រូវផ្តល់ដំណឹងជាលាយល័ក្ខអក្សរដល់អង្គភាពដែលត្រូវចុះទៅត្រួតពិនិត្យឱ្យបានយ៉ាងហោចណាស់មួយអាទិត្យមុនថ្ងៃចុះទៅដល់ការដ្ឋានឬកន្លែងដែលត្រូវទៅត្រួតពិនិត្យ

២០.២. មុនពេលចាប់ផ្តើមចេញដំណើរ ប្រធានក្រុមត្រួតពិនិត្យនៃអគ្គលេខាធិការដ្ឋាន ត្រូវសាកសួរអ្នកទទួលខុសត្រូវរបស់អង្គការប្រតិបត្តិករដែលត្រូវធ្វើការត្រួតពិនិត្យ ដើម្បីទាញការចាប់អារម្មណ៍លើបញ្ហាសំខាន់ៗ

២០.៣. ប្រធានក្រុមត្រួតពិនិត្យត្រូវរៀបចំរបាយការណ៍ដាក់ជូនអគ្គលេខាធិការដ្ឋាន ។ របាយការណ៍នេះត្រូវចំលងជូនទៅអង្គការប្រតិបត្តិករ ។ អគ្គលេខាធិការដ្ឋាន ត្រូវផ្ញើលិខិតជាផ្លូវការទៅអង្គការ

ប្រតិបត្តិករដែលត្រូវត្រួតពិនិត្យនោះជាលាយល័ក្ខអក្សរ ដោយបញ្ជាក់ពីខ្លឹមសារ អនុសាសន៍ តំរង់ទិស ដែលត្រូវធ្វើការកែលំអ និងបញ្ជាក់ពីថេរៈវេលាដែលត្រូវអនុវត្តអនុសាសន៍នេះផង

២០.៤. រាល់របាយការណ៍ត្រួតពិនិត្យ/វាយតំលៃ ដែលរៀបចំដោយ "អាជ្ញាធរ" ត្រូវរក្សាទុកជាការសំងាត់

២០.៥. បញ្ហាដែលត្រូវបានកត់សំគាល់ដោយប្រធានក្រុមត្រួតពិនិត្យ ត្រូវមានការគូសបញ្ជាក់បំភ្លឺ ពីអង្គការប្រតិបត្តិករ ។ បើបញ្ហានោះមានភាពធ្ងន់ធ្ងរ អគ្គលេខាធិការដ្ឋាន ត្រូវអញ្ជើញអង្គការប្រតិបត្តិករនោះ មកធ្វើការបង្ហាញនូវការកែតំរូវលើការគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការ ដោយគោរពយ៉ាងពេញលេញទៅតាមការតំរូវដូចមានចែងក្នុងរបាយការណ៍ ។

## ជំពូកទី ១៣

## យន្តការរៀបចំផែនការ ការត្រួតពិនិត្យ ការអនុវត្តន៍ និង ការគ្រប់គ្រងថវិកា

មាត្រា ២១ :

២១.១. ការរៀបចំផែនការយុទ្ធសាស្ត្រដែលជាចក្ខុវិស័យរយៈពេលវែង នៃសកម្មភាពមីន ក្នុងព្រះរាជាណាចក្រកម្ពុជា ជាភារៈកិច្ចរបស់ "អាជ្ញាធរ" ។ ដើម្បីញ៉ាំងឱ្យខ្លឹមសារនៃផែនការជាយុទ្ធសាស្ត្រនេះគ្របដណ្តប់បានគ្រប់ជ្រុងគ្រប់ជ្រោយ "អាជ្ញាធរ" ត្រូវបង្កើតគណៈកម្មការពិគ្រោះមួយ ដែលមានសមាសភាពដូចតទៅ :

- តំណាងក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- តំណាងក្រសួងការពារជាតិ
- តំណាងក្រសួងមហាផ្ទៃ
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តំណាងអគ្គបញ្ជាការដ្ឋានកងយោធពលខេមរៈភូមិន្ទ/បញ្ជាការដ្ឋានកងវិស្វកម្ម
- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ
- តំណាងក្រសួងផែនការ
- តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន
- តំណាងក្រសួងធនធានទឹក និង ឧតុនិយម

- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- តំណាងអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ដែលពាក់ព័ន្ធនឹងសកម្មភាពមីន
- តំណាងម្ចាស់ជំនួយ

២១.២. តួនាទីការ និងនីតិវិធីចាំបាច់នានា ដែលទាក់ទងនឹងការអភិវឌ្ឍន៍ផែនការយុទ្ធសាស្ត្ររបស់ជាតិ នឹងត្រូវចែងលំអិតក្នុងគោលនយោបាយដោយឡែកដែលចេញដោយ "អាជ្ញាធរ" ។

មាត្រា ២២ :

ផែនការជាយុទ្ធសាស្ត្រនេះ បន្ទាប់ពីបានទទួលការអនុម័តពីនាយករដ្ឋមន្ត្រី នឹងត្រូវចូលជាធរមានក្នុងរយៈពេលមួយសប្តាហ៍បន្ទាប់ពីថ្ងៃចុះហត្ថលេខា ។ ផែនការជាយុទ្ធសាស្ត្រនេះគឺជាផែនការរបស់រាជរដ្ឋាភិបាល ដែលរាល់បណ្តាអង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ត្រូវយកជាមូលដ្ឋានពោលសំរាប់រៀបចំ ឬ សំរបសំរួលផែនការរបស់ខ្លួន ។

មាត្រា ២៣ :

អង្គការប្រតិបត្តិករជាតិ និងអន្តរជាតិសកម្មភាពមីនទាំងអស់ ត្រូវរៀបចំផ្ញើផែនការរយៈពេលខ្លី ឬ រយៈពេលវែងរបស់ខ្លួន មកអគ្គលេខាធិការដ្ឋាន ដើម្បីបញ្ចូលជាមួយផែនការមេរបស់ជាតិ ។

មាត្រា ២៤ :

ប្រតិបត្តិករទាំងអស់ ចាំបាច់ត្រូវអនុវត្តសកម្មភាពទៅតាមផែនការដែលបានអនុម័តហើយ ។ អគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" ត្រូវមានភារកិច្ចត្រួតពិនិត្យឱ្យបានទៀងទាត់ដើម្បីធានាការអនុវត្តន៍ឱ្យចំទិសដៅ ពិសេសស្របទៅនឹងផែនការជាតិ ។

មាត្រា ២៥ :

អគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" ជាមជ្ឈមណ្ឌលជាតិទទួលបន្ទុកគ្រប់គ្រងទិន្នន័យនៃសកម្មភាពមីន នៅព្រះរាជាណាចក្រកម្ពុជា ។ រាល់បណ្តាអង្គការប្រតិបត្តិករទាំងអស់ទាំងសកម្មភាពមីន និង យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ត្រូវផ្ញើសេចក្តីរាយការណ៍ឱ្យបានទៀងទាត់ ប្រចាំត្រីមាស ឆមាស និង ឆ្នាំ មកអគ្គលេខាធិការដ្ឋាន ។ ខ្លឹមសារនៃសេចក្តីរាយការណ៍ ត្រូវមានយ៉ាងហោចសកម្មភាព លទ្ធផលនៃកម្មវិធីនីមួយៗ

របាយការណ៍ហិរញ្ញវត្ថុ និង ពត៌មានស្តីពីស្ថានភាពសេដ្ឋកិច្ច-សង្គមផង ។ តំរូវការចាំបាច់នានាសំរាប់រាយការណ៍ និង ការធ្វើរបាយការណ៍ នឹងមានចែងលំអិតក្នុងគោលនយោបាយដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ។

មាត្រា ២៦ :

ក្រោយពីបានទទួលការសំរេចជាគោលការណ៍ពីគណៈអចិន្ត្រៃយ៍ "អាជ្ញាធរ" អគ្គលេខាធិការមានសិទ្ធិចុះកិច្ចសន្យាបន្តទៅក្រុមហ៊ុន ឬភ្នាក់ងារដែលមានសមត្ថភាពដទៃទៀត ដើម្បីទទួលភារៈកិច្ចផ្ទាល់របស់ខ្លួន ។ នីតិវិធីនៃការចុះកិច្ចសន្យាបន្ត ត្រូវអនុវត្តទៅតាមនីតិវិធី និង គោលការណ៍លទ្ធកម្មរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ១៤
## យន្តការគ្រប់គ្រងដីធ្លីបោសសំអាតមីនហើយ

មាត្រា ២៧ :

ដើម្បីធានានូវការប្រើប្រាស់ដីធ្លីដែលបោសសំអាតមីនហើយ ប្រកបដោយតម្លាភាព និង ប្រសិទ្ធភាពកំរិតខ្ពស់ អង្គការប្រតិបត្តិករទាំងអស់ ត្រូវអនុវត្តទៅតាមបែបបទនៃការរៀបចំផែនការ និង ការគ្រប់គ្រងសកម្មភាពមីន ដែលនឹងមានចែងនៅក្នុងគោលនយោបាយដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ក៏ដូចជាចំពោះនីតិវិធីនានាសំរាប់គ្រប់គ្រងដីធ្លី ដែលចេញដោយអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ។ ផែនការ និង អនុសាសន៍ លំដាប់ខេត្ត ស្រុក ឃុំ ភូមិ ដែលបានឯកភាពនិងលើកឡើង ត្រូវផ្ញើមកអគ្គលេខាធិការ-ដ្ឋាន "អាជ្ញាធរ" ដោយប្រធានគណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត ដើម្បីធ្វើជាមូលដ្ឋានក្នុងការលើកគំរោងលំដាប់ជាតិ និង សំរាប់ធ្វើការត្រួតពិនិត្យ និង តាមដាន ។

មាត្រា ២៨ :

តំរូវការ និង ដំណើរការចាំបាច់នានា ដែលទាក់ទងទៅនឹងការលើកគំរោងសំរាប់កិច្ចប្រតិបត្តិការបោសសំអាតមីន និង ការគ្រប់គ្រងដីធ្លី នឹងមានចែងលំអិតក្នុងគោលនយោបាយដោយឡែក ដែលចេញដោយ "អាជ្ញាធរ" ។

## ជំពូកទី ១៥
## យន្តការគ្រប់គ្រងសេវាកម្ម កិច្ចសង្រ្គោះជនរងគ្រោះដោយសារមីន

**មាត្រា ២៩ :**

រាល់ការគ្រប់គ្រង តាមដាន ត្រួតពិនិត្យសេវាកម្ម និង ការសំរបសំរួលកិច្ចសង្គ្រោះជនពិការដោយសារមីន ជាភារកិច្ចរបស់ "អាជ្ញាធរ" ។ ដោយយន្តការផ្នែកនេះមានដំណើរការហើយ "អាជ្ញាធរ" ប្រគល់ភារកិច្ចសំរបសំរួលនេះទៅក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា និង អង្គការក្រុមប្រឹក្សាសកម្មភាពជនពិការ តាមរយៈការទទួលស្គាល់នូវប្រកាសលេខ ៣០៨ ក.ស.ប.យ. ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៨ ។ "អាជ្ញាធរ" អាចផ្តល់អនុសាសន៍ចំពោះរាល់សកម្មភាពសង្គ្រោះជនពិការដោយសារមីន និង ក្នុងករណីចាំបាច់ "អាជ្ញាធរ" អាចបញ្ជូនតំណាងរបស់ខ្លួនឱ្យទៅចូលរួមក្នុងប្រតិបត្តិការសង្គ្រោះនោះជាមួយអង្គការ និង ភ្នាក់ងារទាំងឡាយដែលទទួលបន្ទុកការងារនេះ ។ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវធ្វើរបាយការណ៍រីកចំរើនប្រចាំត្រីមាស ឆមាស និង ឆ្នាំ មក "អាជ្ញាធរ" អោយបានទៀងទាត់ ។

## ជំពូក ១៦
## សិទ្ធិប្រធានចូលរួមប្រជុំអន្តរជាតិ

**មាត្រា ៣០ :**

ការអនុញ្ញាតិតំណាងរាជរដ្ឋាភិបាលកម្ពុជាឱ្យចូលរួមក្នុងកិច្ចប្រជុំអន្តរជាតិស្តីពីសកម្មភាពមីន ជាសិទ្ធិរបស់នាយករដ្ឋមន្ត្រី ។ រាល់ការស្នើសុំរបស់តំណាងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមកិច្ចប្រជុំនានា ដែលទាក់ទងទៅនឹងសកម្មភាពមីន ចាំបាច់ត្រូវធ្វើលិខិតសុំការអនុញ្ញាតិមក "អាជ្ញាធរ" ។

**មាត្រា ៣១ :**

អគ្គលេខាធិការដ្ឋាននៃ "អាជ្ញាធរ" ត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីចាត់តាំងប្រតិភូទៅចូលរួមប្រជុំនេះ ។ ក្នុងករណីចាំបាច់ អគ្គលេខាធិការ "អាជ្ញាធរ" អាចស្នើសុំក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ចាត់តាំងមន្ត្រីការទូតទៅចូលរួមបាន ។

**មាត្រា ៣២ :**

មន្ត្រីដែលបានអនុញ្ញាតឱ្យទៅចូលរួមសម័យប្រជុំ ត្រូវធ្វើសេចក្តីរាយការណ៍តាមរយៈរដ្ឋមន្ត្រី ឬ តំណាង

ស្ថាប័នពាក់ព័ន្ធផ្ញើមក "អាជ្ញាធរ" ។ របាយការណ៍នេះ ត្រូវសរុបនូវខ្លឹមសារសង្ខេបរបស់កិច្ចប្រជុំ ដោយភ្ជាប់ឯកសារនានា ហើយក្នុងករណីចាំបាច់ត្រូវលើកជាអនុសាសន៍ ឬ សំណើផ្សេងៗផង ។

## ជំពូកទី ១៧

## ពិធីការលើកិច្ចចុះហត្ថលេខាលើកិច្ចព្រមព្រៀង

**មាត្រា ៣៣ :**

"អាជ្ញាធរ" មានតួនាទីតំណាងឱ្យរាជរដ្ឋាភិបាល លើរាល់កិច្ចសន្យា ឬកិច្ចព្រមព្រៀងនានាស្តីពីសកម្មភាពមីន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៣៤ :**

៣៤.១. កម្មវិធី និង គំរោងនានា ដែលទាក់ទងនឹងកិច្ចប្រតិបត្តិការសកម្មភាពមីន ចាំបាច់ត្រូវមានអនុស្សរណៈ រវាង "អាជ្ញាធរ" និង ភ្នាក់ងារផ្តល់ជំនួយ ។

៣៤.២. កិច្ចព្រមព្រៀងផ្តល់ថវិការវាងភ្នាក់ងារផ្តល់ជំនួយ និង អង្គការប្រតិបត្តិករ អាចចុះហត្ថលេខាដោយឡែកបាន ហើយមន្ត្រីនៃ "អាជ្ញាធរ" អាចធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខានេះ ។ ឯកសារដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀងផ្តល់ថវិកាទាំងនេះ ត្រូវផ្ញើមកតំកល់ទុកនៅអគ្គលេខាធិការដ្ឋាននៃ "អាជ្ញាធរ" ។

## ជំពូកទី ១៨

## ការអនុវត្តន៍សន្ធិសញ្ញាអូតាវ៉ា

**មាត្រា ៣៥ :**

"អាជ្ញាធរ" ជាតំណាងរបស់រាជរដ្ឋាភិបាល ហើយត្រូវសហការជាមួយស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីអនុវត្តសន្ធិសញ្ញា អនុសញ្ញា កិច្ចព្រមព្រៀង ឬលិខិតូបករណ៍អន្តរជាតិទាំងឡាយក្នុងការបំពេញកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាទាក់ទងនឹងបញ្ហាមីនប្រឆាំងមនុស្សគ្រប់ប្រភេទ ។

**មាត្រា ៣៦ :**

"អាជ្ញាធរ"ត្រូវកោះអញ្ជើញក្រសួង ស្ថាប័ន អង្គការប្រតិបត្តិករជាតិ និង អន្តរជាតិ ដែលធ្វើប្រតិបត្តិការសកម្មភាពមីន មករួមប្រជុំដើម្បីប្រមូលទិន្នន័យ លទ្ធផល ឬបញ្ហាផ្សេងៗទៀត ដើម្បីរួមចំណែកក្នុងការរៀបចំរបាយការណ៍ជាតិតាមលំនាំបែបបទជាលក្ខណៈអន្តរជាតិ ស្តីពីសកម្មភាពមីន ។ កិច្ចប្រជុំនេះ ត្រូវ

រៀបចំឡើងយ៉ាងហោចណាស់ឱ្យបានមួយខែមុនថ្ងៃកំណត់ ដែលត្រូវធ្វើសេចក្តីរាយការណ៍ទៅអង្គការសហប្រជាជាតិ ។

## ជំពូកទី ២០
## ការអនុវត្តន៍ច្បាប់ ស្តីពីការហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្សគ្រប់ប្រភេទ

**មាត្រា ៣៧ :**

ការអនុវត្តនីច្បាប់ស្តីពីការហាមប្រាមការប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស ត្រូវកំណត់ដោយអនុក្រឹត្យដោយឡែក ។

## ជំពូកទី ២១
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨ :**

"អាជ្ញាធរ" តំរូវឱ្យអង្គការប្រតិបត្តិករសកម្មភាពមីនជាតិ និងអន្តរជាតិ ផ្តល់នូវរបាយការណ៍ស្តីពីអចលនទ្រព្យរបស់ខ្លួន ។ "អាជ្ញាធរ" ជាអ្នកទទួលពេញច្បាប់ នូវអចលនទ្រព្យទាំងឡាយដែលជាផ្នែកនៃកម្មវិធីសំរាប់សកម្មភាពមីន ហើយដែលម្ចាស់ជំនួយផ្ទេរជូនរាជរដ្ឋាភិបាល ។ អង្គការប្រតិបត្តិករសកម្មភាពមីនទាំងអស់ ត្រូវធ្វើលិខិតបញ្ជាក់ជាលាយល័ក្ខអក្សរផ្ញើមកអគ្គលេខាធិការដ្ឋាន "អាជ្ញាធរ" នូវអចលនទ្រព្យដែលម្ចាស់ជំនួយផ្ទេរជូនរាជរដ្ឋាភិបាល ក្នុងរយៈពេលមួយសប្តាហ៍មុនថ្ងៃទទួលដាក់ស្តែង ។ "អាជ្ញាធរ" នឹងធ្វើការត្រួតពិនិត្យ ក្នុងករណីចាំបាច់ដាក់ស្តែងត្រូវចាត់ចែងទុកដាក់នូវអចលនទ្រព្យទាំងនោះទៅតាមច្បាប់ និង បទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣៩ :**

"អាជ្ញាធរ" មានភារកិច្ចទទួលបន្ទុកផ្តួចផ្តើមកិច្ចអភិវឌ្ឍន៍បច្ចេកទេសថ្មីៗដែលសមស្រប ដើម្បីលើកកំពស់ និង ជំរុញសកម្មភាពបោសសំអាតមីនឱ្យមានប្រសិទ្ធិភាពកាន់តែខ្ពស់ឡើង រួមទាំងការស្រាវជ្រាវការពិសោធន៍ ការសាកល្បងគ្រឿងយន្ត និងបច្ចេកទេសថ្មីៗក្នុងព្រះរាជាណាចក្រកម្ពុជា ។ អង្គការដែលមានបំណងអនុវត្តការស្រាវជ្រាវ ការពិសោធន៍ និង ការសាកល្បងនេះ ត្រូវស្នើសុំជាលាយល័ក្ខអក្សរមកអគ្គលេខាធិការ "អាជ្ញាធរ" ។ របាយការណ៍ស្តីពីលទ្ធផលចុងក្រោយត្រូវដាក់ជូនមក "អាជ្ញាធរ" ។

មាត្រា ៤០ :

"អាជ្ញាធរ" នឹងជំរុញឱ្យមានចលនាផ្លាស់ប្តូរគ្នាទៅវិញទៅមកជាមួយនឹងបណ្តាប្រទេសដែលមានបញ្ហាមីន ដើម្បីលើកកំពស់ការហ្វឹកហ្វឺន ការអប់រំ និង សមត្ថភាពបច្ចេកទេសក្នុងប្រទេសកម្ពុជា ជាមួយបណ្តាប្រទេសដែលមានបញ្ហាមីនទាំងនោះ ។

## ជំពូកទី ២១
## អវសានបញ្ញត្តិ

មាត្រា ៤១ :

ក្នុងករណីមានភារកិច្ចដែលទាក់ទងសកម្មភាពមីន មានពាក់ព័ន្ធលើសមត្ថកិច្ចរបស់ស្ថាប័នដទៃ នាយករដ្ឋមន្ត្រីជាអ្នកសំរេចរៀបចំបែងចែកភារកិច្ចរវាង "អាជ្ញាធរ" និង ស្ថាប័នទាំងនោះ ។

មាត្រា ៤២ :

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤៣ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី និង រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤៣
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣២៩ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ជូនឯកឧត្តមឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក និងនាយទាហានជាន់ខ្ពស់ ០៧ រូប ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្ម ក្នុងការស្នើសុំជំនួយពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីស្ថាបនាស្ពានបេតុង ០៣ កន្លែង ប្រវែង ៩៥ ម៉ែត្រ នៅក្នុងស្រុកសំពៅមាស ខេត្តពោធិសាត់ មានតំលៃជាទឹកប្រាក់សរុបចំនួន ៣០០.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ÷

**ក.មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ**

១-ឯកឧត្តមនាយឧត្តមនាវី DENNIS BLAIR អគ្គបញ្ជាការតំបន់ប៉ាស៊ីហ្វិក

២- H.E KENT WIEDE MANN ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំព្រះរាជាណាចក្រកម្ពុជា

**ខ.មេដាយសហមេត្រី ថ្នាក់ សេនា**

- Gen . JOHNS RAY MOND អគ្គបញ្ជាការតំបន់ប៉ាស៊ីហ្វិក

**គ.មេដាយសហមេត្រី ថ្នាក់ អស្សឫទ្ធិ**

១- Col . MICHAEL NORTON អនុព័ន្ធយោធាសហរដ្ឋអាមេរិក

២- Maj . RALPH SKEBA អនុព័ន្ធយោធាសហរដ្ឋអាមេរិក

៣- Maj. JIM DARIENZO ក្រុមបច្ចេកទេសស្ថានកងទ័ពសហរដ្ឋអាមេរិក

៤- IVAN KEOGH ក្រុមពិនិត្យគុណភាព

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៣០ អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ប្រគេន និង ជូនសប្បុរសជន ០៦ រូប ដែលបានចំណាយបច្ច័យ និង ថវិកា ដើម្បីជួយកសាងព្រះវិហារ , ផ្លូវ ស្ថិតនៅក្នុងវត្តវេឡុវ៉ន ស្រុកអង្គស្នួល ខេត្តកណ្តាល ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **ឯក** | **ផា** | គង់នៅវត្តវេឡុវ៉ន បច្ច័យ ២០.០០០ USD |
| ២-ឯកឧត្តម | **ស៊ូ** | **គីមស៊ុន** | ទីប្រឹក្សាអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ថវិកា ២០.០០០ USD |
| ៣-ឯកឧត្តម | **ទ្រី** | **ម៉េង** | អគ្គនាយកបច្ចេកទេសក្រសួងអភិវឌ្ឍន៍ជនបទ ថវិកា ២០.០០០ USD |
| ៤-លោក | **ឡូន** | **សុផល** | ប្រធានគ្រប់គ្រងគំរោងថ្នាក់ជាតិក្រសួងអភិវឌ្ឍន៍ជនបទ ថវិកា ២០.០០០ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **សឺុង ចន្ណា** នៅភ្នំពេញ ថវិកា ៧.៥០០ USD

២-លោក **ឆេត ម៉ូ** នៅភ្នំពេញ ថវិកា ៦.០០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ ៧ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៣៣.១...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនក្នុង និង ក្រៅប្រទេសចំនួន ១៨ រូប ដែលបានជួយឧបត្ថម្ភជាថវិកាផ្ទាល់ខ្លួន ដើម្បីកសាងប្រាសាទវិមានផុសអណ្តែតឥន្ទ្រព្រហ្ម - បុរីស្រីព្រះវេស្សន្តរ ស្ថិតនៅក្នុងភូមិដីឥដ្ឋកោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ÷

**ក-មេដាយមាសស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោកវរសេនីយ៍ឯក | **ខួន** | **សុវណ្ណារ៉ា** | ថវិកាចំនួន | ១០.៥០០ USD |
| ២-លោក | **ខួច** | **ជីឡុង** | ថវិកាចំនួន | ១០.៥០០ USD |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-លោក | **ឌុត** | **សារឿន** | ថវិកាចំនួន | ៧.៥០០ USD |
| ២-លោក | **យ៉ែម** | **យ៉ន** | ថវិកាចំនួន | ៦.៨០០ USD |
| ៣-លោក | **សំ** | **ផនខៅ** | ថវិកាចំនួន | ៦.២០០ USD |
| ៤-លោក | **សំរិទ** | **ហេង** | ថវិកាចំនួន | ៦.០០០ USD |
| ៥-លោក | **អ៊ឹង** | **ហ៊ុយម៉េង** | ថវិកាចំនួន | ៦.០០០ USD |

| | | | | |
|---|---|---|---|---|
| ៦-លោក | ឃឹម | សុវណ្ណ | ថវិកាចំនួន | ៥.៣០០ USD |
| ៧-កញ្ញា | ខួន | ម៉េងឃី | ថវិកាចំនួន | ៥.២០០ USD |
| ៨-លោក | សុវ | ឡាំ | ថវិកាចំនួន | ៥.០០០ USD |
| ៩-លោក | អៀង | ស៊ុនហួត | ថវិកាចំនួន | ៥.០០០ USD |

**ខ-មេដាយសិរីវឌ្ឍនាជាតិ :**

| | | | | |
|---|---|---|---|---|
| ១-ឧបាសិកា | គង់ | សុខ | ថវិកាចំនួន | ២.៨០០ USD |
| ២-ឧបាសិកា | ភាក់ | សឿន | ថវិកាចំនួន | ២.៤០០ USD |
| ៣-ឧបាសិកា | ជំនែ | ឌីន | ថវិកាចំនួន | ២.៣០០ USD |
| ៤-លោក | ឯក | ឌឹម | ថវិកាចំនួន | ២.១០០ USD |
| ៥-ឧបាសក | មាស | មួន | ថវិកាចំនួន | ២.១០០ USD |
| ៦-លោក | សែម | ឃឿន | ថវិកាចំនួន | ២.១០០ USD |
| ៧-លោក | លន់ | រស្មី | ថវិកាចំនួន | ២.១០០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ ៧ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៨៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការជូនមេដាយស្ថាបនាជាតិ

* * * *

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

**សំរេច**

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៦ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានា ក្នុងវត្តល្បើន ឃុំដូនស , វត្តស្មោ ឃុំឈើទាល , វត្តស្វាយព្រហូត និង វត្តប្រឡាយដូនលែប ឃុំគោកព្រីង ស្ថិតនៅក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ ÷

| | | | | |
|---|---|---|---|---|
| ១-លោក | **ពៅ** | **លីមមី** | និងលោកស្រី | ថវិកាចំនួន ១៨.៥០០ USD |
| ២-លោក | **នុត** | **សាខន** | និងលោកស្រី | ថវិកាចំនួន ១៨.០០០ USD |
| ៣-ឯកឧត្ដម | **ចាន់** | **ទីវ៉ន** | និងលោកជំទាវ | ថវិកាចំនួន ១៦.៥០០ USD |
| ៤-លោក | **ដួង** | **សារឿន** | និងលោកស្រី | ថវិកាចំនួន ១៥.២០០ USD |
| ៥-លោកតា | **ស** | **ម៉ិត** | | ថវិកាចំនួន ១២.០០០ USD |
| ៦-លោកយាយ | **ម៉ក់** | **សែម** | | ថវិកាចំនួន ១០.០០០ USD |

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៣៣៣ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជន ០៥ រូប ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីកសាង សមិទ្ធផលនានា ស្ថិតក្នុងវត្តល្វើន ឃុំដូនស និងវត្តគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម ÷

**ក. មេដាយមាសស្ថាបនាជាតិ :**

១-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចៅ** **គិរុណ** និង លោកជំទាវ ថវិកា ៤០.០០០ USD

២-លោក **សួន** **ចឿន** ថវិកា ១៥.០០០ USD

៣-លោក **ស៊ិន** **សំផល** និង លោកស្រី ថវិកា ១១.៥០០ USD

៤-លោក **ម៉ៃ** **ជាចុង** និង លោកស្រី ថវិកា ១០.៨០០ USD

**ខ. មេដាយសំរិទ្ធស្ថាបនាជាតិ :**

-លោក **កែវ** **សុគី** និង លោកស្រី ថវិកា ២.៥០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៣៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសិរីវឌ្ឍស្ថាបនាជាតិ** ប្រគេនព្រះតេជគុណ ០២ ព្រះអង្គ ដែលបានចំណាយបច្ច័យផ្ទាល់ព្រះអង្គ ដើម្បីកសាងវត្តអារាម ស្ថិតនៅក្នុងស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ដូចមានរាយព្រះនាមខាងក្រោម ÷

១-ព្រះតេជគុណ **ខាត់ ចិន្តា** ព្រះអនុគណសង្ឃ ស្រុកកំពង់រោទិ៍ និង ជាចៅអធិការវត្តត្រពាំងត្រាវ ឃុំញរ បច្ច័យចំនួន ៣.២១០ USD

២-ព្រះតេជគុណ **មាស ម៉ុនធឿន** ព្រះវិន័យធរសង្ឃស្រុកកំពង់រោទិ៍ និង ជាចៅអធិការវត្តព្រៃធ្លក ឃុំស្វាយតាយាន បច្ច័យចំនួន ៣.១០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ.ថ្ងៃទី ០៦ ខែ ៧ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៥ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

******

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០២ រូប ដែលបានជួយកសាងសមិទ្ធផលនានា ដូចជាកសាងសាលាសុធម្មា , ចេតិយ៍តំកល់អដ្ឋិធាតុជនរងគ្រោះ , ជួសជុលនិងកសាងដំបូលព្រះវិហារ និង ទិញដីដាក់វត្ត ស្ថិតនៅក្នុងវត្តព្រៃធ្លក ឃុំស្វាយតាយាន ស្រុកកំពង់រោទ៍ ខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោម ៖

១-លោកវរសេនីយ៍ឯក **ឈោម សន** ប្រធានការិយាល័យប្រេងឥន្ធនៈរបស់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ថវិកា ១៧.០០០ USD

២-លោកស្រី **លឹម សុខៀន** ថវិកា ១០.២០០ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ, ថ្ងៃទី... ខែ... ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៣៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សម្រេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០៣ រូប ដែលបានបរិច្ចាគបច្ច័យ និង ថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានាក្នុងវិស័យព្រះពុទ្ធសាសនា ដូចជាកសាងដំបូលព្រះវិហារ បណ្ណាល័យសិក្សា កុដិ របងវត្ត ផងទង់សាសនា ហោត្រ័យ ឧបដ្ឋានសាលា និងឈាបនដ្ឋាន ស្ថិតនៅក្នុងស្រុកពញាឮ ខេត្តកណ្តាល ដូចមានរាយព្រះនាម និង នាមខាងក្រោម ÷

១-ព្រះវិចិត្រសត្ថា **ច្រឹក អេង** ព្រះរាជាគណៈថ្នាក់កិត្តិយស និង ជាព្រះចៅអធិការវត្តសុវណ្ណរាសីរតនារាម បច្ច័យចំនួន ៨៣.៧១៥ USD

២-ព្រះគ្រូជោត្តមុនី **ឈឹម សុខាត់** គ្រូសូត្រស្តាំវត្តជោត្តមង្គល បច្ច័យចំនួន១៤៥.៣០០ USD

៣-លោក **យោគ ឈា** ប្រធានមន្ទីរពតិមានរាជធានីភ្នំពេញ ថវិកាចំនួន ៩៩.៥០៣ USD

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០១ ខែ ៧ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៣៧ អនក្រ-តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តស្វាយរៀង

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៦ រូប ដែលបានចំណាយ នូវថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានា នៅក្នុងទីរួមខេត្តស្វាយរៀង ដូចមានរាយនាមខាងក្រោមនេះ ÷

១-ឯកឧត្តម **ខ្វាន់ ស៊ាម** និងលោកជំទាវ ថវិកាចំនួន ១២.៥០០ ដុល្លារអាមេរិក
២-ឯកឧត្តម **ពៅ ផារី** និងលោកជំទាវ ថវិកាចំនួន ១១.២០០ ដុល្លារអាមេរិក
៣-ឯកឧត្តម **ថែម សុវណ្ណនី** និងលោកជំទាវ ថវិកាចំនួន ១០.០០០ ដុល្លារអាមេរិក
៤-លោក **ពូត សយ** និងលោកស្រី ថវិកាចំនួន ១០.០០០ ដុល្លារអាមេរិក
៥-លោក **មុំ លន់** និងលោកស្រី ថវិកាចំនួន ១០.០០០ ដុល្លារអាមេរិក
៦-លោក DIETER TRENKER ថវិកាចំនួន ១០.០០០ ដុល្លារអាមេរិក

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តស្វាយរៀង ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០១

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៣៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូនលោកតា **គង់ លង់** ដែលបានផ្តួចផ្តើម និងចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីសាងសង់នូវប្រាសាទវិមានផុសអំណ្តែតឥន្ទ្រព្រហ្មបូរីស្រី-ព្រះវេស្សន្តរ បានហើយជាស្ថាពរក្នុងរយៈពេល ៣១ ខែ អស់ទឹកប្រាក់ចំនួន ២៥៣.៦០០ USD និង ៤៧.៦៩០.០០០ រៀល ស្ថិតនៅភូមិដីឥដ្ឋ កោះផុស ឃុំដីឥដ្ឋ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៣៩ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

* * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **ស៊ី ហៃឡុង** (SHI HAILONG) និង លោក **ចាង យី** (ZHANG YI) តំណាងប្រធានក្រុមខួងអណ្តូងស្នប់ នៃសាធារណរដ្ឋប្រជាមានិតចិន ដែលបានជួយអភិវឌ្ឍន៍ប្រទេសកម្ពុជាលើវិស័យទឹកស្អាត ដោយបានកសាងជីកអណ្តូងស្នប់ពីរលើក ហើយក្នុងមួយលើកៗចំនួន ៥០០ អណ្តូង ស្មើនឹងទឹកប្រាក់ចំនួន ១៦.០០០.០០០ យន់ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤០ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភណ្ឌ

******

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកណ្តាល

### សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភណ្ឌ** ថ្នាក់ **សេនា** ជូនលោកឧកញ៉ា **ចក់ ឡេង** ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ដើម្បីជួយកសាងសមិទ្ធផលនានាលើវិស័យព្រះពុទ្ធសាសនា និង គមនាគមន៍ ដូចជា កសាងព្រះវិហារ, ដងទង់, របងវត្ត, ធ្វើផ្លូវលំមួយខ្សែប្រវែង ៥.៣០០ ម៉ែត្រ និង ចាក់ដីបំពេញវត្ត ស្ថិតនៅក្នុងវត្តសិរីជ័យមង្គល ហៅវត្តគោហី ស្រុកមុខកំពូល ខេត្តកណ្តាល សរុបទឹកប្រាក់ចំនួន ១៤០.៩០០ ដុល្លារអាមេរិក, ២៧.០០០.០០០ រៀល និង មាស ០៣ ដំឡឹង ៧ ជី ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៣៤១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនលោក **អេង ហេងលី** សប្បុរសជននៅខេត្តបាត់ដំបង ដែលបានចំណាយថវិកាផ្ទាល់ខ្លួន ជួយកសាងក្លោងទ្វារ និង របងអនុវិទ្យាល័យ ព្រះនរោត្តមរណឫទ្ធិ ក្នុងស្រុកកំពត ខេត្តកំពត មានតំលៃជាទឹកប្រាក់សរុបចំនួន ៥.៧០០ ដុល្លារអាមេរិក ។

៩- ឯកឧត្តម តាន់ សិទ្ធនូ អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
១០- ឯកឧត្តម ទា សុថ្មា អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
១១- ឯកឧត្តម ប៊ុន ណារិទ្ធ អគ្គនាយកអាជ្ញាធរអប្សរា សមាជិក

**គ- ក្រុមការងារផ្នែកកម្មន្តសាល និងចែកចាយ**

១- ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធាន
២- ឯកឧត្តម សុក ស៊ីផាណា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម អនុប្រធាន
៣- ឯកឧត្តម កៀង វ៉ាង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក
៤- ឯកឧត្តម ជី កាយី អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- ឯកឧត្តម យី យ៉ូន អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
៦- ឯកឧត្តម ព្រហ្ម សិទ្ធត្រា អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក
៧- ឯកឧត្តម អៀម រ៉ា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
៨- ឯកឧត្តម ទេព លន់ អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
៩- ឯកឧត្តម អ៊ុក ចាន់ អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
១០- ឯកឧត្តម សយ សុខា អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច- សង្គមកិច្ចនិងវប្បធម៌ សមាជិក
១១- ឯកឧត្តម សួន សិទ្ធី អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

**ឃ- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច**

១- ឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន

២- ឯកឧត្តម គង់ វិបុល រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៣- ឯកឧត្តម សុខ ចិន្តា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៤- ឯកឧត្តម វ័ន្ត សារិន អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក

៥- ឯកឧត្តម ស្វាយ ស៊ីថា អនុរដ្ឋលេខាធិការទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សមាជិក

៦- ឯកឧត្តម អ៊ុំ ប៊ុនធឿន អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

៧- ឯកឧត្តម គឹម ស៊ីថន អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

៨- ឯកឧត្តម ញ៉ឹក ច្រឹង អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៩- ឯកឧត្តម អ៊ិត ណូឌី អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

១០- ឯកឧត្តម វង់ សូត អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក

១១- លោកជំទាវ ឌិម សោមស៊ុន អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ សមាជិក

១២- ឯកឧត្តម ប៉ុល លឹម អគ្គាធិការរងទី ១ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល នៃក្រសួងមហាផ្ទៃ សមាជិក

**ង- ក្រុមការងារផ្នែកសេវាគាំទ្របញ្ចូលធាតុចូលសេវាធនាគារ និងហិរញ្ញវត្ថុ :**

១- ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ប្រធាន

២- ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុប្រធាន

៣- ឯកឧត្តម ឯម សំអាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៤- ឯកឧត្តម សុខ ចិន្តា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៥- ឯកឧត្តម សៅ សុកខុន អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក

៦- ឯកឧត្តម នូ មុត អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា សមាជិក

៧- ឯកឧត្តម នូវ ភារិទ្ធ អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក

៨- ឯកឧត្តម សួង ហេង អនុរដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក

៩- ឯកឧត្តម សុទ្ធ សុធន្ទ អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ សមាជិក

១០- ឯកឧត្តម ឡា ណារ៉ាត អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក

១១- ឯកឧត្តម ឈឹម ណារិទ្ធ អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម សមាជិក

១២- ឯកឧត្តម កែវ សាផល អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

១៣- ឯកឧត្តម សយ សុខា អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច- សង្គមកិច្ច និងវប្បធម៌ សមាជិក

**ច- ក្រុមការងារផ្នែកថាមពល និងហេដ្ឋារចនាសម្ព័ន្ធ**

១- ឯកឧត្តម យី តាំងលឹម រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ប្រធាន

២- ឯកឧត្តម អ៊ិត ប្រាំង រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អនុប្រធាន

៣- ឯកឧត្តម ខូវ ម៉េងហ៊ាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ សមាជិក

៤- ឯកឧត្តម ញាណ ឡេង អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- ឯកឧត្តម ប៊ុន អ៊ុយ អនុរដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៦- ឯកឧត្តម កួយ គឹមស៊ា អនុរដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
៧- ឯកឧត្តម កែវ ខេមរា អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក
៨- ឯកឧត្តម តុំ ប៊ុននឿន អនុរដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម សមាជិក
៩- ឯកឧត្តម ប្រាជ្ញ ស៊ុន អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
១០- ឯកឧត្តម ជា ឆាយ អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល សមាជិក
១១- ឯកឧត្តម កែវ សាផល អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក
១២- ឯកឧត្តម សួន សិទ្ធី អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា សមាជិក

**ឧ- ក្រុមការងារផ្នែកផលិតកម្មកែច្នៃដើម្បីនាំចេញ**

១- ឯកឧត្តម ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធាន
២- ឯកឧត្តម អះម៉ាត់ យ៉ះយ៉ា រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
៣- ឯកឧត្តម សុខ ចិន្តា អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
៤- ឯកឧត្តម សួរ វិចទ័រ អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៥- ឯកឧត្តម សេង លឹមនៅ អនុរដ្ឋលេខាធិការទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
៦- ឯកឧត្តម តេង ឡៅ អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
៧- ឯកឧត្តម សយ ស៊ីផុន អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សមាជិក
៨- ឯកឧត្តម ខួត ភ័ន្ទី អនុរដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក
៩- ឯកឧត្តម រ័ត្ន សណ្ដាប់ អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន សមាជិក
១០- ឯកឧត្តម ម៉ៅ ហាវណ្ណាល់ អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល សមាជិក

**ប្រការ ២** : ក្រុមការងារនីមួយៗ មានភារកិច្ចសំខាន់ៗដូចតទៅ ÷

- ពិភាក្សាផ្លាស់ប្តូរយោបល់ជាមួយផ្នែកឯកជន ដើម្បីលើកឡើងនូវវិធានការដោះស្រាយ រាល់បាតុភាពអសកម្ម ដែលកើតមានក្នុងក្របខ័ណ្ឌវិស័យរបស់ខ្លួន អោយបានទាន់ពេលវេលា និងលើកជាសំណូមពរដោះស្រាយជូនស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធក្នុងករណីចាំបាច់ ។
- ពិនិត្យពិចារណាជាមួយវិស័យឯកជនជាដៃគូរ ក្នុងការលើកឡើងនូវរាល់គំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រសំរាប់គាំទ្រលើកទឹកចិត្តបណ្តាក្រុមហ៊ុនកំពុងមានសកម្មភាព ក៏ដូចជាសំរាប់ទាក់ទាញការវិនិយោគថ្មីៗបន្ថែមទៀតមកកម្ពុជា ។
- ធ្វើរបាយការណ៍ជាប្រចាំជូនប្រមុខរាជរដ្ឋាភិបាល ពីសភាពការណ៍ការងារ និងពីទិសដៅភារកិច្ចដែលត្រូវអនុវត្តជាបន្តដើម្បីមានជាមូលដ្ឋានសំរាប់ប្រមុខរាជរដ្ឋាភិបាលផ្តល់ជាអនុសាសន៍នៅរៀងរាល់វេទិការាជរដ្ឋាភិបាល-វិស័យឯកជន ។
- ទទួលដោះស្រាយរាល់ការចាំបាច់ផ្សេងៗទៀត ក្នុងក្របខ័ណ្ឌវិស័យរបស់ខ្លួន តាមការប្រគល់ភារកិច្ចរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៣** : ភារកិច្ចរបស់ក្រុមការងារនីមួយៗ មានវិសាលភាពគ្របដណ្តប់លើការងារ ដែលមានកំណត់ក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយសេចក្តីសំរេចនេះ ។

**ប្រការ ៤** : អគ្គលេខាធិការដ្ឋានសំរាប់បំរើយន្តការរាជរដ្ឋាភិបាល-វិស័យឯកជន នឹងត្រូវបង្កើតព្រមទាំងឧបត្ថម្ភដោយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ។ ក្នុងពេលរង់ចាំការបង្កើតអគ្គលេខាធិការដ្ឋាននេះ ប្រធានក្រុមការងារនីមួយៗអាចបង្កើតលេខាធិការដ្ឋាននៅតាមក្រសួង- ស្ថាប័នរបស់ខ្លួន ដោយប្រើប្រាស់មន្ត្រីរបស់ខ្លួនជាលេខាធិការ និងដោយប្រើប្រាស់ជាផ្លូវការនូវត្រារបស់ក្រសួង- ស្ថាប័នក្នុងកិច្ចទំនាក់ទំនងរាល់ការងារក្នុងក្របខ័ណ្ឌភារកិច្ច ដែលបានកំណត់ក្នុងប្រការ ២ នៃសេចក្តីសំរេចនេះ ។

**ប្រការ ៥** : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាចំណុចកណ្តាលសំរាប់ធ្វើទំនាក់ទំនងអន្តរក្រុមការងារ និងសរុបរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ។

**ប្រការ ៦** : សមាជិកក្រុមការងារនីមួយៗ ត្រូវចូលរួមប្រជុំអោយបានទៀងទាត់ តាមការអញ្ជើញរបស់ប្រធាន ។ ពេលប្រធានអវត្តមាន ក្រុមការងារអាចប្រជុំក្រោមអធិបតីភាពរបស់អនុប្រធានឬរបស់តំណាង តាមការប្រគល់សិទ្ធិរបស់ប្រធាន ។

**ប្រការ ៧** : សេចក្តីសំរេចលេខ ០៧ / សសរ / ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០១ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨** : សេចក្តីសំរេចលេខ ៣៣ / សសរ / ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០១ នៅរក្សាទុកជាធរមាន ។

**ប្រការ ៩** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនឹងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

ចម្លងជូន :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៩*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៥ សសរ

## សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតគណៈកម្មាធិការរៀបចំថ្នាក់ជាតិ ចូលរួមក្នុងសន្និសីទកំពូលស្ដីពីការអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំ ២០០២

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ៥៧ / អនក្រ.បក / ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងបរិស្ថាន
- ដោយអនុលោមតាមទិសដៅសន្និសីទអង្គការសហប្រជាជាតិស្ដីពីបរិស្ថាន និងការអភិវឌ្ឍន៍ ដែលបានប្រព្រឹត្តទៅនៅទីក្រុង Rio de Janeiro ឆ្នាំ ១៩៩២
- យោងតាមសំណើរបស់ក្រសួងបរិស្ថាន និងការងាររបស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការរៀបចំថ្នាក់ជាតិមួយ ដើម្បីសំរបសំរួល រៀបចំត្រៀមចូលរួមក្នុងសន្និសីទកំពូល ស្ដីពីការអភិវឌ្ឍន៍ដោយចីរភាព ឆ្នាំ ២០០២ នៅទីក្រុង Johannesburg ប្រទេសអាហ្វ្រិក ខាងត្បូង ។

**ប្រការ ២** : សមាសភាពគណៈកម្មាធិការនេះរួមមាន :

| | |
|---|---|
| ១- ក្រសួងបរិស្ថាន | ជាប្រធាន |
| ២- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ជាសមាជិក |
| ៣- ក្រសួងផែនការ | ជាសមាជិក |
| ៤- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាសមាជិក |
| ៥- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ជាសមាជិក |
| ៦- ក្រសួងទេសចរណ៍ | ជាសមាជិក |
| ៧- ក្រសួងអភិវឌ្ឍន៍ជនបទ | ជាសមាជិក |
| ៨- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ជាសមាជិក |
| ៩- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| ១០- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| ១១- គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ | ជាសមាជិក |

គណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាល ចូលរួមប្រជុំផ្តល់យោបល់ តាមការចាំបាច់ ។

**ប្រការ ៣** : គណៈកម្មាធិការនេះមានភារៈកិច្ចដូចតទៅ :

ក- រៀបចំឯកសារស្តីពីការវាយតំលៃថ្នាក់ជាតិ អំពីកិច្ចខិតខំប្រឹងប្រែង និងទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការអភិវឌ្ឍន៍ដោយចិរភាព ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច

ខ- រៀបចំសន្និសីទ ត្រៀមសំរាប់តំបន់អាស៊ីប៉ាស៊ីហ្វិក ដែលនឹងប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ពីថ្ងៃទី ២៧ ដល់ ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ មុនសន្និសីទកំពូលស្តីពីការអភិវឌ្ឍន៍ដោយចិរភាព ។

**ប្រការ ៤** : គណៈកម្មាធិការ ត្រូវសហការទំនាក់ទំនងអោយបានជិតស្និតជាមួយក្រុមការងារតំបន់នៃសន្និសីទកំពូលស្តីពីការអភិវឌ្ឍន៍ដោយចិរភាព ដែលក្នុងនោះមាន ESCAP UNEP UNDP និងធនាគារអភិវឌ្ឍន៍អាស៊ី ADB ភ្នាក់ងាររបស់អង្គការសហប្រជាជាតិ ដៃគូរទ្វេភាគីតំណាងសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល សាកលវិទ្យាល័យ និងភាគីពាក់ព័ន្ធដ៏ទៃទៀត ។

**ប្រការ ៥** : គណៈកម្មាធិការនេះមានលេខាធិការដ្ឋានមួយជាជំនួយការ ដែលមានទីតាំងនៅក្រសួងបរិស្ថាន ។

**ប្រការ ៦** : លេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះ ត្រូវបានដឹកនាំដោយលេខាធិការមួយរូប ហើយមានអ្នកជំនាញការជាតិ និងអន្តរជាតិបន្ថែមមួយចំនួនទៀត តាមតំរូវការចាំបាច់ ដើម្បីអនុវត្តការងារតាមភារកិច្ចដែលគណៈកម្មាធិការប្រគល់អោយ ។ គណៈកម្មាធិការនេះមានសិទ្ធប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ។

**ប្រការ ៧ :** ខ្លឹមសារនៃការវាយតំលៃថ្នាក់ជាតិ ត្រូវផ្តោតជាអាទិ៍ទៅលើ :

១- ការវាយតំលៃពីសភាពការណ៍នៃការអនុវត្តន៍យុទ្ធសាស្ត្រ គន្លឹះគំនិតផ្តួចផ្តើម ការអភិវឌ្ឍន៍ដោយចិរភាពនៅកម្ពុជា ក៏ដូចជាការអនុវត្តន៍ និងការប្រតិបត្តិរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះកិច្ចការអន្តរជាតិដែលទាក់ទងនឹងការអភិវឌ្ឍន៍ដោយចិរភាព

២- កំណត់ពីបញ្ហាគន្លឹះ និងបទពិសោធដែលទទួលបាន

៣- ផ្អែកលើមូលដ្ឋាននៃការវាយតំលៃនេះ ត្រូវលើកឡើងពីចក្ខុវិស័យទៅអនាគតរបស់រាជរដ្ឋាភិបាលកម្ពុជា ចំពោះការអភិវឌ្ឍន៍ដោយចិរភាព ។

**ប្រការ ៨ :** ក្នុងការរៀបចំឯកសារស្តីពីការវាយតំលៃថ្នាក់ជាតិ គណៈកម្មាធិការត្រូវយកចិត្តទុកដាក់ ជាអាទិ៍លើកិច្ចដំណើរការដូចខាងក្រោមនេះ :

- រៀបចំសិក្ខាសាលាសំរាប់អ្នកដែលពាក់ព័ន្ធសំខាន់ៗ ដើម្បីជួយកំណត់វិសាលភាព និងវិធីសាស្ត្រនៃការវាយតំលៃ និងរបៀបដែលត្រូវអនុវត្ត
- ចាត់តាំងអ្នកសំរបសំរួល ដើម្បីដឹកនាំកិច្ចដំណើរការវាយតំលៃដោយមានជំនួយគាំទ្រពីជំនាញការអន្តរជាតិ ហើយអាចបន្ថែមជំនាញការជាតិ និងអន្តរជាតិមួយចំនួនទៀត ទៅតាមតំរូវការជាក់ស្តែង
- ពិគ្រោះយោបល់ដើម្បីកំណត់អំពីបញ្ហាគន្លឹះ បទពិសោធន៍ដែលបានទទួល និងកំណត់ចក្ខុវិស័យទៅអនាគតរបស់រាជរដ្ឋាភិបាលកម្ពុជា ពីបញ្ហាចិរភាព
- រៀបចំសេចក្តីព្រាង និងបញ្ចប់របាយការណ៍ ។
- សមាជិកគណៈកម្មាធិការនេះ ត្រូវចូលប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មាធិការ

**ប្រការ ៩ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនឹងសេចក្តីសំរេចនេះ ត្រូវសហការអនុវត្តអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១*

ហ៊ុន សែន

*ចម្លងជូន :*

*-ក្រសួងព្រះបរមរាជវាំង*

*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*

*-ដូចប្រការ ៩*

*-កាលប្បវត្តិ-ឯកសារ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...៨៦.សសរ

## សេចក្តីសំរេច

ស្តីពី

ការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើស

ក្រុមប្រឹក្សាឃុំ-សង្កាត់ ហៅកាត់ «ការិយាល័យសន្តិសុខថ្នាក់កណ្តាល»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៣០១ / ០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានបង្កើតគណៈបញ្ជាការ ការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ហៅកាត់ «ការិយាល័យសន្តិសុខថ្នាក់កណ្តាល» ដែលមានសមាសភាពដូចតទៅ ៖

- ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា — ប្រធាន
- ឯកឧត្តម ទៀ បាញ់ ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ — អនុប្រធាន
- ឯកឧត្តម យូ ហុកគ្រី ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ — សមាជិក
- ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន សហរដ្ឋមន្ត្រីក្រសួងការពារជាតិ — សមាជិក
- ឯកឧត្តម ទា ចំរ៉ាត់ ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកការងារការពារសន្តិសុខ សណ្តាប់ធ្នាប់សំរាប់ការបោះឆ្នោត — សមាជិក
- ឯកឧត្តម កែ គឹមយ៉ាន អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ — សមាជិក
- ឯកឧត្តម ហុក ឡុងឌី អគ្គនាយកនគរបាលជាតិ — សមាជិក
- ឯកឧត្តម សៅ សុខា មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស — សមាជិក

**ប្រការ ២** : ការិយាល័យសន្តិសុខថ្នាក់កណ្តាល មានភារកិច្ច និងសមត្ថកិច្ចចូលរួមសហការ និងសំរបសំរួល ជាមួយអនុគណៈកម្មាធិការផ្នែកសន្តិសុខ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

- ចាត់តាំងកម្លាំងជំនាញមានសមត្ថកិច្ច ចុះសហការអោយបានជិតស្និទ្ធជាមួយយន្តការផ្នែកសន្តិសុខតាមឋានានុក្រម ដើម្បីធានាអោយការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ ប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា ។
- ផ្សព្វផ្សាយពត៌មាន គោលការណ៍ វិធានការសន្តិសុខ ជូនទៅការិយាល័យសន្តិសុខថ្នាក់ក្រោម ។
- ប្រមូលផ្តុំពត៌មានពាក្យបណ្តឹងទាក់ទិននឹងសន្តិសុខពីការិយាល័យសន្តិសុខខេត្ត- ក្រុង ដើម្បីពិនិត្យដោះស្រាយ និងធ្វើការបញ្ជាណែនាំ ។

**ប្រការ ៣ :** ការិយាល័យសន្តិសុខថ្នាក់កណ្តាលមានសិទ្ធិបង្កើតលេខាធិការដ្ឋាន ដើម្បីជាជំនួយក្នុងការតាមដានដឹកនាំបញ្ជា និងមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី ។

- ប្រមូលផ្តុំ ចាត់ចែងប្រើប្រាស់សំភារៈឧបករណ៍ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទរបស់អង្គភាពផ្ទាល់ដែលមានស្រាប់ ដើម្បីរួមចំណែកអនុវត្តកិច្ចប្រតិបត្តិការការពារសន្តិសុខសណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈអោយមានប្រសិទ្ធភាពខ្ពស់ ដល់ដំណើរការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់ ។

**ប្រការ ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងសមាសភាពដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
- *ដូចប្រការ ៤*
- *ឯកសារ- កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៤៧ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបន្ថែមសមាសភាពគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ - សង្កាត់ ហៅកាត់ « ការិយាល័យសន្តិសុខថ្នាក់កណ្តាល »

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០៣០១ / ០៤ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ- សង្កាត់
- បានឃើញសេចក្តីសំរេចលេខ ៤៦ / សសរ / ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០១ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ - សង្កាត់ ហៅកាត់ «ការិយាល័យសន្តិសុខថ្នាក់កណ្តាល»
- យោងតាមតម្រូវការចាំបាច់ការងាររបស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១** : ត្រូវបានបន្ថែមសមាសភាពឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាសមាជិក គណៈបញ្ជាការការពារការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ - សង្កាត់ ហៅកាត់ «ការិយាល័យសន្តិសុខថ្នាក់កណ្តាល» ។

**ប្រការ ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងឯកឧត្តម អ៊ុក រ៉ាប៊ុន ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០១

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- ដូចប្រការ ២
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ...៤៧...សសរ

## សេចក្តីសំរេច

## ស្តីពីការបង្កើតក្រុមការងារ

## សំរាប់រៀបចំ គោលនយោបាយអភិវឌ្ឍន៍ថាមពល និងឧស្ម័នជាតិ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១:** បង្កើតក្រុមការងារមួយសំរាប់រៀបចំគោលនយោបាយអភិវឌ្ឍន៍វិស័យថាមពល និងឧស្ម័នជាតិ ដែលមានសមាភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម សុខ អាន | រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ២. | ឯកឧត្តម ស៊ុយ សែម | រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៣. | ឯកឧត្តម ឆាន់ សាផាន់ | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| ៤. | ឯកឧត្តម សារ៉ាក់ ខាន់ | អនុរដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៥. | ឯកឧត្តម សុខ ចិន្តា | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៦. | ឯកឧត្តម ទី នរិន្ទ | ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា | សមាជិក |
| ៧. | ឯកឧត្តម តែ ដួងតារា | អគ្គនាយកអាជ្ញាធរប្រេងកាតជាតិកម្ពុជា | សមាជិក |
| ៨. | ឯកឧត្តម សយ សុខា | អគ្គលេខាធិការក្រុមសង្កេតការណ៍ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | សមាជិក |

៩. លោក ចាន់ សូដាវ៉ាត់ អនុប្រធាននាយកដ្ឋានផែនការយុទ្ធសាស្ត្រ និងគំរោងការ នៃក្រុមហ៊ុនអគ្គិសនីកម្ពុជា — សមាជិក

១០. តំណាងសមាគមន៍កិច្ចព្រមព្រៀងប្រេងកាតមានលក្ខខ័ណ្ឌ (CPAA) — សមាជិក

១១. តំណាងប្រតិបត្តិករសម្បទានិកនៃតំបន់ប្រេងកាតដែនសមុទ្រកម្ពុជា — សមាជិក

១២. តំណាង Consortium (Siemens, Unocal and Egco) — សមាជិក

**ប្រការ ២:** ក្រុមការងារនេះមានភារកិច្ច :

- រៀបចំកសាងឯកសារគោលនយោបាយ សំរាប់ការអភិវឌ្ឍន៍ថាមពលអគ្គិសនី និង ឧស្ម័នជាតិ ។
- សំរបសំរួលការពិគ្រោះយោបល់ក្នុងភាពជាដៃគូ រវាងស្ថាប័នរាជរដ្ឋាភិបាលជាមួយផ្នែកឯកជន ។
- វាយតំលៃអំពីសមត្ថភាពផ្តល់ឧស្ម័នដល់រោងចក្រផលិតថាមពលអគ្គិសនី សំរាប់ដំណើរការបញ្ជូន និង ចែកចាយអគ្គិសនីតាមខ្សែបណ្តាញបញ្ជូនអគ្គិសនីភាគខាងត្បូង ។
- ផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលអំពីលក្ខខ័ណ្ឌបច្ចេកទេស ហិរញ្ញវត្ថុ ពាណិជ្ជកម្ម ច្បាប់ និងលក្ខខ័ណ្ឌផ្សេងៗទៀត សំរាប់ការជំរុញការអភិវឌ្ឍន៍ ថាមពលអគ្គិសនី និងឧស្ម័នជាតិ ។
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារជូនរាជរដ្ឋាភិបាលទៅតាមដំណាក់កាលការងារនិមួយៗ ។

**ប្រការ ៣:** ប្រធានក្រុមការងារមានសិទ្ធិជ្រើសរើសសមាជិកមួយរូបទទួលចាត់ចែងការងារជំនួសក្នុងពេលអវត្តមាន ។

**ប្រការ ៤:** សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៥:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានអាជ្ញាធរប្រេងកាតជាតិកម្ពុជា ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា ប្រធាននិងសមាជិកក្រុមការងារ ដែលបានរាយនាមក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ៧ ឆ្នាំ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ដូចប្រការ ៥ (ដើម្បីអនុវត្ត)*
*-ឯកសារ-កាលប្បវត្តិ*


CASE 13A (modified)
UNOCAL 76
KAMPOT
HON DAT
O MON
TRA NOC
SOC TRANG
AN MINH
CA MAU
HO CHI MINH
5 km-26"
110 km-26"
40 km-16"
260 km-26"
UNOCAL
BLOCK B
VIETNAM
ENTERPRISE
PEDCO
OPECO
CANADIAN PETROLEUM
I:\NVAFDG\Map030301.ppt, 15-May-01 page 2

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០៤.សរ

# សារាចរ

## ស្តីពី

## ការចាត់តាំងរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក និងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៨ នៃទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា

*

* ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក នឹងត្រូវប្រព្រឹត្តទៅចំនួន ៣ ថ្ងៃ គឺថ្ងៃ ១៤-១៥កើត និងថ្ងៃ ១ រោច ខែកត្តិក ត្រូវនឹងថ្ងៃទី ៣០-៣១ ខែតុលា និងថ្ងៃទី ១ ខែវិច្ឆិកា ឆ្នាំ ២០០១ ជាព្រះរាជពិធីមួយក្នុងបណ្តាព្រះរាជពិធីទ្វាទសមាសប្រចាំឆ្នាំ ដែលតែងតែប្រារព្ធរៀងរាល់ឆ្នាំនៅប្រទេសកម្ពុជា ។ ដើម្បីបើកឱកាសជូនប្រជារាស្ត្រសប្បាយរីករាយ ចូលរួមថែរក្សានូវប្រពៃណីរបស់ជាតិ ដែលជាប់ទាក់ទងទៅនឹងប្រវត្តិពិធីសមយុទ្ធនៃកំលាំងសាមគ្គីកងទ័ពជើងទឹករបស់យើងក្នុងបុព្វហេតុការពារមាតុភូមិ និងសំដែងនូវមនោសញ្ចេតនាប្រកបដោយកតញ្ញូតាធម៌ចំពោះមហាករុណាទិគុណនៃព្រះរតនត្រ័យ ពពួកទេវតា និងវត្ថុស័ក្តិសិទ្ធិ ដែលបានគាំពារ និងជួយឧបត្ថម្ភឱ្យវិស័យកសិកម្មជាតិមានការរីកចំរើនរុងរឿង ព្រមទាំងជាឱកាសបួងសួងសុំឱ្យបារមីនៃព្រះពុទ្ធជាម្ចាស់ និងវត្ថុស័ក្តិសិទ្ធិទាំងអស់បន្តជួយឧបត្ថម្ភវិស័យកសិកម្មនារដូវខាងមុខ ឱ្យទទួលបានជោគជ័យ និងទិន្នផលខ្ពស់ជាងបណ្តាឆ្នាំកន្លងទៅទៀតផង ។

* ពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៨ នៃទិវាបុណ្យឯករាជ្យជាតិ នឹងត្រូវប្រព្រឹត្តទៅ នៅថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ២០០១ ដើម្បីសំដែងមនោសញ្ចេតនាអបអរសាទរ រំលឹកទិវាជាប្រវត្តិសាស្ត្រ ដែលកំលាំងមហាសាមគ្គីជាតិទាំងមូលដណ្តើមបានទាំងស្រុងមកវិញ ពីអាណានិគមនិយមបារាំង នាឆ្នាំ១៩៥៣ នូវឯករាជ្យជាតិដ៏ពិតប្រាកដ ក្រោមព្រះរាជបូជនីយកិច្ចដ៏ថ្លៃថ្លានៃ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ។

ដើម្បីចាត់តាំងរៀបចំពិធីបុណ្យទាំងពីរនេះ ឱ្យបានសមរម្យ ស័ក្តិសមទៅនឹងអត្ថន័យដ៏ជ្រាលជ្រៅដូចបានបញ្ជាក់ខាងលើនេះ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដាក់ចេញនូវសារាចរណែនាំអនុវត្តដូចតទៅ ÷

### ១- <u>អំពីព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក</u> :

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សហការជាមួយក្រសួងពាក់ព័ន្ធ និងខេត្ត-ក្រុង ចាត់តាំងរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នៅតាមដងទន្លេសាប នៅវេទិកាព្រះរាជពិធីបុណ្យអុំទូក មុខព្រះបរមរាជវាំង ក្នុងរយៈកាល ៣ថ្ងៃ តាមប្រពៃណីជាតិ ប្រពៃណីសាសនា ដោយមានចាត់តាំងក្រសួង ស្ថាប័នមួយចំនួន រចនាតុបតែងជាប្រទីប មានអុចកាំជ្រួចភ្លឺទៀន មានតាំងភ្លើងពណ៌រៀងរាល់យប់នៅរាជធានីភ្នំពេញ ។

-ត្រូវមានផែនការណែនាំលំអិតជាក់ស្តែង ស្តីពីល័ក្ខខ័ណ្ឌទាំងឡាយ នៃការជ្រើសរើសទូក ង ដែលត្រូវចូលរួមប្រណាំង ដោយត្រូវកំណត់ទូកអុំ-ទូកចែវ ឱ្យបានច្បាស់លាស់ និងត្រូវធ្វើសេចក្តីអំពាវនាវ សប្បុរសជន បណ្តាក្រុមហ៊ុនឯកជន ឱ្យជួយឧបត្ថម្ភជា សម្ភារៈ ថវិកា សម្រាប់ជូនរង្វាន់ដល់កីឡាករអុំទូក ។

-ខេត្ត-ក្រុង ដែលមានទូក ង ចូលរួមប្រណាំង ត្រូវធ្វើការសាកល្បងហ្វឹកហាត់ចម្រាញ់ជ្រើសរើសទូក ដែលមានចំណាត់ថ្នាក់ជាទូកលឿនរបស់ខេត្ត-ក្រុង ក្នុងចំនួនសមស្រប សម្រាប់ចូលរួមប្រណាំងនៅរាជធានីភ្នំពេញ ។

២. **អំពីពិធីបុណ្យឯករាជ្យជាតិ :**

-ត្រូវចាត់តាំងរៀបចំពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី ៤៨ នៃទិវាឯករាជ្យជាតិ ៩ វិច្ឆិកា ក្នុងកម្រិតរូបភាពមួយដ៏មហោឡារិក ស័ក្តិសមទៅនឹងកិត្តិយសប្រទេសជាតិ ដោយមានចាត់តាំងមីទ្ទិញមហាជនមួយ នៅបរិវេណវិមានឯករាជ្យ មានថ្នាក់ដឹកនាំជាតិ-មន្ត្រីរាជការ-សិស្សានុសិស្ស និងភ្ញៀវអន្តរជាតិ ចូលរួមអោយបានច្រើនកុះករ និងមានចាត់តាំងពិធីដុតទៀនជ័យ, ដាក់កម្រងផ្កា គោរពវិញ្ញាណក្ខន្ធ និងពន្លត់ទៀនជ័យនៅវិមានឯករាជ្យ ព្រមទាំងមានបង្ហោះប៉េងប៉ោងលែងព្រាបជានិមិត្តរូប នៃការសុំសុខសន្តិភាពផង ។

-ខេត្ត.ក្រុង ត្រូវចាត់តាំងពិធីមីទ្ទិញមហាជន និងពិធីគោរពវិញ្ញាណក្ខន្ធ នៅតាមទីកន្លែងដ៏សមគួរ តាមការជាក់ស្តែងរបស់ខេត្ត-ក្រុង នីមួយៗ ។

-គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ និងអន្តរជាតិ ត្រូវរៀបចំកម្មវិធីសម្រាប់ថ្នាក់ដឹកនាំក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចុះសួរសុខទុក្ខ យុទ្ធជនរបួស មានជម្ងឺ កំពុងសម្រាកព្យាបាលនៅតាមមន្ទីរពេទ្យ យុទ្ធជនពិការនៅតាមអគារយុទ្ធជនពិការ កុមារកំព្រា នៅតាមមណ្ឌលកុមារកំព្រា ដោយបាននាំអំណោយជួយឧបត្ថម្ភ និងបំផុសឱ្យគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន ស្ថាប័ន ចងបដា ពាក្យស្លោក ដោតទង់ជាតិ ទង់ក្ដោប និងតុបតែងលំអភ្លើងពណ៌ ឱ្យបានឧឡារិក ។

-ត្រូវបូកសរុប គំរោងថវិកាចំណាយលំអិត ដែលក្រសួងពាក់ព័ន្ធបានលើកឡើងក្នុងស្មារតីសន្សំសំចៃ ឆ្អែតប្រឱតខ្ពស់ ផ្ញើជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសំរេច ។

-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវចាត់តាំងរៀបចំកម្មវិធីសិល្បៈ ធ្វើការណែនាំដល់មន្ត្រីវប្បធម៌ខេត្ត-ក្រុង ចាត់តាំងក្រុមតន្ត្រីសិល្បៈបុរាណ សម័យ និងចំរៀង បុរាណ សម័យ សំដែងជូនប្រជារាស្ត្រទស្សនាកំសាន្ត នៅតាមទីសាធារណៈ អបអរសាទរក្នុងពិធីបុណ្យទាំងពីរខាងលើ ។

-ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវត្រៀមលក្ខណៈដោះស្រាយសម្ភារៈ និងថវិកាសម្រាប់បំរើការរៀបចំពិធីបុណ្យទាំងពីរខាងលើ ឱ្យបានសមស្រប និងទាន់ពេលវេលា ។

-ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ត្រូវត្រៀមលក្ខណៈចាត់តាំងការពារសន្តិសុខ របៀបរៀបរយសណ្តាប់ធ្នាប់សង្គម ចរាចរ តាមសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាសុវត្ថិភាព និងសេចក្តីសប្បាយរីករាយជូនប្រជាពលរដ្ឋយើង ។

ទទួលបានសារាចរនេះ សូមឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន គ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន ស្ថាប័នពាក់ព័ន្ធ និងអភិបាលខេត្ត-ក្រុង ចាត់តាំងអនុវត្តឱ្យបានសំរេចលទ្ធផលល្អប្រសើរ ស្របតាមគោលបំណង និងសំណូមពរ ហើយធ្វើរបាយការណ៍បូកសរុបជូនរាជរដ្ឋាភិបាល ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ៨ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
" ដើម្បីជូនជ្រាប "
-គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន-ស្ថាប័ន
និងខេត្ត-ក្រុង
" ដើម្បីសហការអនុវត្ត
-ឯកសារ

# ពាក្យស្លោកសម្រាប់ប្រើប្រាស់
# ក្នុងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក
# និងពិធីបុណ្យឯករាជជាតិ ឆ្នាំ ២០០១

---

១- សូមថ្វាយព្រះពរព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា មានព្រះរាជសុខុមាលភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរ ។

២- សូមថ្វាយព្រះពរសម្តេចឪ និងសម្តេចម៉ែ សូមមានព្រះជន្មាយុយឺនយូរ ។

៣- ជយោ ! សម្តេចឪ និងសម្តេចម៉ែ ។

៤- អបអរសាទរយ៉ាងក្លៀវក្លា ខួបអនុស្សាវរីយ៍លើកទី ៤៨ ទិវាបុណ្យឯករាជជាតិ ៩ វិច្ឆិកា " ០៩-១១-១៩៥៣ - ០៩-១១-២០០១ "

៥- ចងចាំជានិច្ច នូវព្រះរាជបូជនីយកិច្ចទាមទារឯករាជជាតិដ៏ឧត្តុង្គឧត្តមរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ។

៦- ជយោ ! លិទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស នៅព្រះរាជាណាចក្រកម្ពុជា ។

៧- ជយោ ! សន្តិភាព និងការបង្រួបបង្រួមជាតិ ។

៨- ជយោ ! ព្រះរាជាណាចក្រកម្ពុជា ។

៩- ជាតិ សាសនា ព្រះមហាក្សត្រ ។

១០- អបអរសាទរ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក ។

១១- អបអរសាទរ លទ្ធផលនៃការអនុវត្តន៍កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ។

១២- ជយោ ! សន្តិភាព និងការអភិវឌ្ឍន៍ ។

១៣- ជយោ ! សម្តេចព្រះរាជបិតាឯករាជជាតិ ។

១៤- ជយោ ! សម្តេចព្រះបិតាសន្តិភាព ផ្សះផ្សាជាតិ និងបង្រួបបង្រួមជាតិ ។ ៕

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០១ សជណ

# សេចក្តីអំពាវនាវ

ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមទូលព្រះបង្គំ-ខ្ញុំផ្ទាល់, ទូលព្រះបង្គំ-ខ្ញុំ សូមទូលថ្វាយ សម្តេច ព្រះអង្គម្ចាស់, អ្នកអង្គម្ចាស់ និងសូមជម្រាបជូន ឯកឧត្តម លោកអ្នកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ជាពាណិជ្ជករ អាជីវករ សិប្បករ វិនិយោគិន សប្បុរសជនជាតិ និងអន្តរជាតិទាំងអស់ ព្រះមេត្តា និងមេត្តាជ្រាបថា ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នឹងប្រព្រឹត្តទៅរយៈពេល ៣ ថ្ងៃ គឺថ្ងៃ ១៤-១៥ កើត និងថ្ងៃ ១រោច ខែកត្តិក ត្រូវនឹងថ្ងៃទី ៣០-៣១ ខែតុលា និង ០១ ខែវិច្ឆិកា ឆ្នាំ ២០០១ ខាងមុខនេះ ។ ដើម្បីបើកឱកាសជូនប្រជាពលរដ្ឋសប្បាយរីករាយ ចូលរួមថែរក្សានូវប្រពៃណីរបស់ជាតិ ដែលជាប់ទាក់ទងទៅនឹងប្រវត្តិពិធីសមយុទ្ធនៃកំលាំងសាមគ្គីកងទ័ពជើងទឹករបស់យើង ក្នុងបុព្វហេតុការពារមាតុភូមិ និងសំដែងមនោសញ្ចេតនាប្រកបដោយកតញ្ញូតាធម៌ ចំពោះមហាករុណាទិគុណនៃព្រះរតនត្រ័យ ពពួកទេវតា និងវត្ថុស័ក្តិសិទ្ធិដែលបានគាំពារ និងជួយឧបត្ថម្ភឱ្យវិស័យកសិកម្មជាតិ មានការចំរើនរុងរឿង ព្រមទាំងជាឱកាសបួងសួងសូមឱ្យបារមីនៃព្រះពុទ្ធជាអម្ចាស់ និងវត្ថុស័ក្តិសិទ្ធិទាំងនោះ បន្តជួយឧបត្ថម្ភវិស័យកសិកម្មនារដូវខាងមុខ ទទួលបានទិន្នផលខ្ពស់ជាងនេះថែមទៀត ។

សូមទូលថ្វាយ និងសូមជម្រាបជូនថា ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូកខាងមុខនេះ នឹងមានទូកនិងកីឡាករអុំទូកជាច្រើនមកពីបណ្តាខេត្ត-ក្រុង ចូលរួមប្រណាំងអបអរសាទរ ហើយក៏នឹងមានរៀបចំជារង្វាន់សម្រាប់ជូនដល់ទូកដែលបានទទួលជ័យលាភី និងរង្វាន់លើកទឹកចិត្តដល់ក្រុមកីឡាករទូកទាំងអស់ផងដែរ ។

អាស្រ័យហេតុនេះ សូមសម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកអ្នកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី និងសប្បុរសជនទាំងអស់ ព្រះមេត្តានិងមេត្តាជួយឧបត្ថម្ភជាថវិកា ឬជាសម្ភារៈមាន : ខោ អាវ មួក កន្សែង សារុង ក្រមា បារី ភេសជ្ជៈ និងសម្ភារៈប្រើប្រាស់ផ្សេងៗទៀត តាមសទ្ធាជ្រះថ្លា ដើម្បីបានជូនជារង្វាន់ដល់ក្រុមកីឡាករទូក ១ ផង និងដើម្បីរួមចំណែកបំរើការរៀបចំពិធីបុណ្យប្រពៃណីជាតិយើង អោយប្រព្រឹត្តទៅអធិកអធមផង ។

គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ រង់ចាំទទួលអំណោយដ៏សប្បុរសរបស់ សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី គ្រប់ពេលម៉ោងធ្វើការ នៅទីស្នាក់ការលេខ ៣៨៩ តិរវិថីព្រះស៊ីសុវត្ថិ មុខព្រះបរមរាជវាំង ជិតព្រះអង្គដងកើ ។

សូមថ្វាយព្រះពរ ជូនពរ ចំពោះសម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី សប្បុរសជនទាំងអស់ ប្រកបដោយពុទ្ធពរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ នឹង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។/.

ធ្វើនៅភ្នំពេញ, ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

* **បញ្ជាក់បន្ថែម :**

រាល់ជំនួយឧបត្ថម្ភ សូមមេត្តាធ្វើទំនាក់ទំនងទៅឯកឧត្តម មិន ឃិន អគ្គលេខាធិការ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ

តាម Fax/P : 855 23 212 957

Tel : 016 834752

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
N° ៤១៧ រ.ប.ត.ឧ.ត.ស-ប្រក

រាជធានី-ភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០០១

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ. ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩១ ស្តីពីការគ្រប់គ្រងឧស្សាហកម្មតូច និង សិប្បកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញប្រកាសលេខ ៩០២ ប្រក.ផក ចុះថ្ងៃទី ១៣-១០-៩៩ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើសុំ បន្តដំណើរការឧស្សាហកម្មតូចបញ្ចូលឧស្ម័នសំរាប់ចង្ក្រានហ្គាស"អណ្តាតភ្លើង" របស់លោក *MAITREE YIM YAM* ចុះថ្ងៃទី ៣០-៥-០១ ។

# សំរេច

**ប្រការ១:-** អនុញ្ញាតអោយក្រុមហ៊ុន"ស៊ូភើហ្គាស" SUPER GAS Co., Ltd ដែលមានលោក *MAITREE YIM YAM* ជនជាតិថៃ កាន់លិខិតឆ្លងដែនលេខ M228052 ចុះថ្ងៃទី ១៥-៣-៩៤ ជាប្រធាន អាស័យដ្ឋានស្នាក់នៅបច្ចុប្បន្ន ទីស្នាក់ការក្រុមហ៊ុន ផ្លូវជាតិលេខ៥ ភូមិដូង ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល បន្តដំណើរការ ឧស្សាហកម្មតូចបញ្ចូលឧស្ម័នសំរាប់ចង្ក្រានហ្គាស"អណ្តាតភ្លើង" នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

**ប្រការ២:-** ប្រកាសនេះមានតំលៃក្នុងរយៈពេលបីឆ្នាំ ។ ផុតកំណត់នេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ បង្កអោយមានការប៉ះពាល់ដល់បរិស្ថាន ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ៣:-** ប្រកាសលេខ ៩០២ ប្រក.ផក ចុះថ្ងៃទី ១៣-១០-៩៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៤:-** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និង លោក *MAITREE YIM YAM* ត្រូវទទួលអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ៥:-** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ចំលងជូន:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្ត កណ្តាល
-សាលាស្រុក ពញាឮ
"ដើម្បីជ្រាប"
-ដូចប្រការ ៤ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion king

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry,Mines and Energy

N° ៥៧២១ ឧសថ៣ក-ប្រក

រាជធានី-ភ្នំពេញ,ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០១

26 9 14h36 339

# ប្រកាស

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ. បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- បានឃើញលិខិតលេខ ៨៧៧ /០១ គ.វ.ក ចុះថ្ងៃទី ២០.០៣.២០០១ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។
- បានឃើញប្រកាសលេខ ១៧៨ ប.ស្ក.ប្រ.ក វិបាបស្ថ ចុះថ្ងៃទី ២៧.០៧.២០០១ របស់ក្រសួងបរិស្ថាន ។
- បានឃើញលិខិតលេខ ១១២ ឧរថកឧ.លស ចុះថ្ងៃទី ២៩.០១.២០០១ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ខេ &អេ ហ្គាមេន ហ្វេកធើរី ខូ អិលធីឌី ចុះថ្ងៃទី ០៥.០៧ .២០០១។

## សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន " ខេ &អេ ហ្គាមេន ហ្វេកធើរី ខូ អិលធីឌី " ( K&A GARMENT CO., LTD.) តំណាងដោយលោក KONG TSZ KA អាយុ ៤៩ ឆ្នាំ ភេទប្រុស សញ្ជាតិ អង់គ្លេស កាន់លិខិតឆ្លងដែនលេខ 611151903 ចុះថ្ងៃទី 30.06.94 បង្កើតរោងចក្រ "កាត់ដេរសំលៀកបំពាក់ " ដែលមានផ្លាកឈ្មោះថា "ខេ &អេ ហ្គាមេន " មានទិតាំងស្ថិតនៅអតិតរោងចក្រតម្បាញទី២ ផ្លូវជាតិលេខ៥ គីឡូម៉ែត្រលេខ៦ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ ទូរសារ : (៨៥៥) ២៣-៤២៨ ២៦៣

45 Preah Norodom Boulevard Khan Daun Penh,Phnom Penh (Cambodia) Tel / Fax (855) 23-428 263

ប្រការ២ : ក្រុមហ៊ុនត្រូវរៀបចំរោងចក្រទៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ឱ្យបានសំរេចក្នុងរយៈពេល ១២ខែ ដោយរាប់បញ្ចូលទាំងរយៈពេលសាកល្បងផង ។

ប្រការ៣ : រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "កាត់ដេរសំលៀកបំពាក់" ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ៤ : ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥ : ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៧: ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

ប្រការ៨ : ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរ នឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវអស់សុពលភាព ។

ប្រការ៩ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន ខេ&អេ ហ្គាមេន ហ្វេកធើរី ខូ អិលធីឌី ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀង១ខ្លួន ។

ប្រការ១០ : ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រាជកិច្ច
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងសង្គមកិច្ច-ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
- ក្រសួងបរិស្ថាន
- ក្រសួងពាណិជ្ជកម្ម
- សាលាក្រុងភ្នំពេញ

"ដើម្បីជូនជ្រាបជាពត៌មាន"

- ដូចប្រការ ៩ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No ៧១៣ MoC / M 2001

ភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១

# ប្រកាស

## ស្តីពីលទ្ធផល នៃ ការដេញថ្លៃកូតាសំរាប់នាំចេញ សំលៀកបំពាក់ទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០១

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញរាជក្រមលេខ នស / រកម / ០១៩៦ / ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ។
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម ។
- យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញវាយនភ័ណ្ឌ និង ផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ឡែន សរសៃសិប្បនិម្មិតធ្វើពីដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និង សរសៃល្បាយសូត្រ រវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមកិច្ចប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃទី ២៩ ខែ មករា ឆ្នាំ ១៩៩៩ ។
- យោងតាមប្រកាសក្រសួងពាណិជ្ជកម្មលេខ ២០៥ MoC/M2001 ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការដាក់អោយដេញថ្លៃ លើកូតាសំលៀកបំពាក់ដែលត្រូវនាំចេញទៅកាន់សហរដ្ឋអាមេរិក ក្នុងឆ្នាំ ២០០១ ។
- យោងតាមការចាំបាច់នៃការងារ ។

# សំរេច

**ប្រការ ១ :** ទទួលស្គាល់លទ្ធផលនៃការដេញថ្លៃកូតា តាមប្រភេទសំលៀកបំពាក់នីមួយ ៗ សំរាប់ការនាំចេញទៅកាន់សហរដ្ឋអាមេរិកក្នុងឆ្នាំ ២០០១ ដែលបានប្រព្រឹត្តទៅនាថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០០១ នៅទីស្តីការក្រសួងពាណិជ្ជកម្ម ដូចមានចែងនៅក្នុងឧបសម្ព័ន្ធ A ។

**ប្រការ ២ :** ក្រុមហ៊ុនទាំងឡាយដែលមានចែងក្នុងឧបសម្ព័ន្ធ A នៃប្រការ ១ ត្រូវបង់ប្រាក់បន្ថែម ៩០% អោយបានមុនថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០១ ។ ការខកខានបង់ នឹងអាចនាំអោយមានការរឹបអូសប្រាក់កក់ ១០% និងការបង្វិលកូតាដេញបានយកទៅទុកដេញថ្លៃ នៅលើកក្រោយវិញ ។

**ប្រការ ៣ :** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណៈកម្មការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**ចម ប្រសិទ្ធ**

**ចំលងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច ការងារ-បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា
  "ដើម្បីជ្រាបជាពតិមាន"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ANNEX - A** ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE 10:31 AM, 8/8/01

MINISTRY OF COMMERCE

TENDER of QUOTA

## TENDER of QUOTA
## August 8, 2001

| ID | COMPANY NAME | 334/634 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 11,000 | $4.00 | | | |
| 1 | Flying Dragon Co Ltd | 2,500 | $7.00 | $17,500.00 | $1,750.00 | $15,750.00 |
| 2 | QMI Industrial Co Ltd | 6,300 | $7.00 | $44,100.00 | $4,410.00 | $39,690.00 |
| 3 | Vinstar Garment Industry Co Ltd | 2,000 | $7.00 | $14,000.00 | $1,400.00 | $12,600.00 |
| 4 | Kennetex International Cambodia Co Ltd | 33 | $6.50 | $214.50 | $21.45 | $193.05 |
| 5 | Duson Cambodia Co LTd | 100 | $6.50 | $650.00 | $65.00 | $585.00 |
| 6 | Tai Yar Garment Industry Co Ltd | 67 | $6.50 | $435.50 | $43.55 | $391.95 |
| | TOTAL | 11,000 | | $76,900.00 | $7,690.00 | $69,210.00 |

| ID | COMPANY NAME | 335/635 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 2,800 | $5.00 | | | |
| 1 | Kin Tai Garment Co Ltd | 295 | $30.00 | $8,850.00 | $885.00 | $7,965.00 |
| 2 | You Cheng Garment Co Ltd | 1,100 | $18.00 | $19,800.00 | $1,980.00 | $17,820.00 |
| 3 | QMI Industrial Co Ltd | 300 | $18.00 | $5,400.00 | $540.00 | $4,860.00 |
| 4 | Yashin Industries Ltd | 700 | $17.00 | $11,900.00 | $1,190.00 | $10,710.00 |
| 5 | Yubin Services Co Ltd | 405 | $16.00 | $6,480.00 | $648.00 | $5,832.00 |
| | TOTAL | 2,800 | | $52,430.00 | $5,243.00 | $47,187.00 |

| ID | COMPANY NAME | 338/339 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 29,000 | $5.00 | | | |
| 1 | Sam Han Cambodia Fabric Co Ltd | 29,000 | $8.00 | $232,000.00 | $23,200.00 | $208,800.00 |
| | TOTAL | 29,000 | | $232,000.00 | $23,200.00 | $208,800.00 |

| ID | COMPANY NAME | 340/640 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 60,000 | $1.00 | | | |
| 1 | Ocean Garment Cambodia Co Ltd | 4,500 | $1.50 | $6,750.00 | $675.00 | $6,075.00 |
| | TOTAL | 4,500 | | $6,750.00 | $675.00 | $6,075.00 |

| ID | COMPANY NAME | 345 QUANTITY OF TENDER | | | | |
|---|---|---|---|---|---|---|
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 13,000 | $5.00 | | | |
| 1 | Century Rich Co Ltd | 2,000 | $6.00 | $12,000.00 | $1,200.00 | $10,800.00 |
| 2 | Universal Apparel Cambodia Co Ltd | 613 | $6.00 | $3,678.00 | $367.80 | $3,310.20 |
| 3 | Sam Han Cambodia Fabric Co Ltd | 1,000 | $5.00 | $5,000.00 | $500.00 | $4,500.00 |
| 4 | Fortune Garment Woolen Knitting Co LtdCo Ltd | 220 | $5.00 | $1,100.00 | $110.00 | $990.00 |
| | TOTAL | 3,833 | | $21,778.00 | $2,177.80 | $19,600.20 |

10:31 AM, 8/8/01

**ANNEX - A**

ក្រសួង ពាណិជ្ជកម្ម - MINISTRY OF COMMERCE

| ID | COMPANY NAME | 445/446 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 20,000 | $2.00 | | | |
| 1 | Universal Apparel Cambodia Co Ltd | 437 | $3.00 | $1,311.00 | $131.10 | $1,179.90 |
| 2 | Sam Han Cambodia Fabric Co Ltd | 3,000 | $2.00 | $6,000.00 | $600.00 | $5,400.00 |
| | TOTAL | 3,437 | | $7,311.00 | $731.10 | $6,579.90 |

| ID | COMPANY NAME | 638/639 | | | | |
|---|---|---|---|---|---|---|
| | | QUANTITY OF TENDER | | | | |
| | | QUANTITY | PRICE | TOTAL | TOTAL10% | TOTAL90% |
| | | 60,000 | $1.00 | | | |
| 1 | Splendid Chance Int'l Ltd | 10,000 | $1.50 | $15,000.00 | $1,500.00 | $13,500.00 |
| 2 | Yubin Services Co Ltd | 5,000 | $1.50 | $7,500.00 | $750.00 | $6,750.00 |
| 3 | Yashin Industries Ltd | 25,000 | $1.00 | $25,000.00 | $2,500.00 | $22,500.00 |
| | TOTAL | 40,000 | | $47,500.00 | $4,750.00 | $42,750.00 |